# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៥-១១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១១១២/៩៥៨ ស្ដីពី ការតែងតាំងឯកឧត្តម **ជាញ៉ូ សារី** ជា អគ្គលេខាធិការរងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៨៣៧៤

០៥-១១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១១១២/៩៥៩ ស្ដីពី ការតែងតាំង ឯកឧត្តមបណ្ឌិត **ឈុន ខណ្ឌៈ** ជាអគ្គលេខាធិការក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង មានឋានៈស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៨៣៧៥

០៥-១១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១១១២/៩៦១ ស្ដីពី ការតែងតាំងឯកឧត្តម **ផែន សុខិដ្ឋារោ** ជាអនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និង ដឹកជញ្ជូន ៨៣៧៦

០៥-១១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១១១២/៩៦២ ស្ដីពី ការតែងតាំងលោកជំទាវ **ទូច សុគន្ធ** ជាអនុរដ្ឋលេខាធិការ ទីស្ដីការគណៈរដ្ឋមន្ត្រី ៨៣៧៧

០៥-១១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/១១១២/៩៦៥ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ចំពោះ នាយទាហាន នៃកងទ័ពប្រជាជនវៀតណាម ចំនួន ០២ រូប ៨៣៧៨


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


៣០-១០-២០១២-អនុក្រឹត្យលេខ ១៩៣ អនក្រ.បក ស្ដីពី ការធ្វើអនុបយោគ ប្ដូរចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ៨៣៧៩

៣០-១០-២០១២-អនុក្រឹត្យលេខ ១៩៤ អនក្រ.បក ស្ដីពី ការបង្កើតអនុគណៈកម្មការទទួលភារកិច្ចរៀបចំព្រះរាជពិធីបុណ្យព្រះបរមសពព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និង ឯកភាពជាតិខ្មែរ ៨៣៨១

០១-១១-២០១២-អនុក្រឹត្យលេខ ១៩៥ អនក្រ.បក ស្ដីពី ការប្រែក្លាយមន្ទីរពេទ្យព្រះអង្គឌួង ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ៨៣៨៨

១០-១០-២០១២-អនុក្រឹត្យលេខ **១៦៥០** ដល់អនុក្រឹត្យលេខ **១៦៦៣** អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៨៤០២

## ២-សេចក្ដីសម្រេច

០១-១១-២០១២-សេចក្ដីសម្រេចលេខ ៤២ សសរ ស្ដីពី ការបង្កើតរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ ៨៤១៦

០៤-១១-២០១២-សេចក្ដីសម្រេចលេខ ៤៣ សសរ ស្ដីពី ការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៨៤១៩

## III-ការងារបណ្ដាក្រសួង

### ១-ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២២-៨-២០១២ -ប្រកាសលេខ ៤៥២ ឧសហវ ស្ដីពី ការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ៨៤២០

### ២-ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០៨-១០-២០១២-ប្រកាសលេខ ៥៥៨ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន លី ឈួង សំណង់ & អាហារ៍ណ នីហារ៍ណ បង្កើតរោងចក្រ ផលិតបន្ទះក្រាល ៨៤៦៦

០៨-១០-២០១២-ប្រកាសលេខ ៥៥៩ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វេង យី (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៨៤៧០

០៨-១០-២០១២-ប្រកាសលេខ ៥៦០ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ប្រ៊ីលលាន ស៊ូហ្វេកធើរី បង្កើតរោងចក្រ ផលិតស្បែកជើង ៨៤៧៤

### ៣-ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៥-៧-២០១១ -លិខិតបញ្ជាក់លេខ ៣៧៨៣ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ខេ.អិល ខារហ្គោ អិចប្រេស ៨៤៧៨

០៥-៧-២០១១ -លិខិតបញ្ជាក់លេខ ៣៧៨៥ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ស្ពេសល អ៊ិនធើណេសិនណល អេនធើប្រាយ ៨៤៨០

០៥-៧-២០១១ -លិខិតបញ្ជាក់លេខ ៣៧៨៦ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ធេលីថេត ស៊ីលូសិន ៨៤៨២

០៥-៧-២០១១ -លិខិតបញ្ជាក់លេខ ៣៧៨៧ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ឌិន រ៉ែត្ត អ៊ីមផត អិចផត ៨៤៨៤

០៥-៧-២០១១ -លិខិតបញ្ជាក់លេខ ៣៧៨៨ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន មីត ខឡួន: ខនស្រ្តាក់សិន ៨៤៨៦

០៥-៧-២០១១ -លិខិតបញ្ជាក់លេខ ៣៧៩០ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផាយឡិន អេនជីនារីង (ខេមបូឌា)** ៨៤៨៨

០៥-៧-២០១១ -លិខិតបញ្ជាក់លេខ ៣៧៩២ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន 8 **ធី** 8 **ត្រេឌីង អិលធីឌី** ៨៤៩០

០៧-៧-២០១១ -លិខិតបញ្ជាក់លេខ ៣៧៩៤ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិម.អ.ស៊ី.អាយ. ខូអប តើរេសិន** & **អ៊ិនខេសមេន** ៨៤៩២

# ព្រះរាជក្រឹត្យ

នស/រកត/១១១២/៩៥៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១២/៩២៥ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តម **ជាញ់ សេរី** ជាអគ្គលេខាធិការរងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ:៩១៩ ប.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១២
**អគ្គលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី/ទីស្តីការគណៈរដ្ឋមន្ត្រីទីភ្នាក់ងារទីស្តីការ រដ្ឋាភិបាល**

**សយ សុខា**

ពរសា.១២១១.៩៥៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២

# ព្រះរាជក្រឹត្យ

នស/រកត/១១១២/៩៥៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១២/៩២៥ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តមបណ្ឌិត **ឈុន វណ្ណៈ** ជាអគ្គលេខាធិការក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ៩២០ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០១២
**អគ្គលេខាធិការ[illegible]រាជរដ្ឋាភិបាល**

[illegible]យ សុខា**

៣៣៧.១២១១.៩៦៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០១២*

# ព្រះរាជក្រឹត្យ

នស/រកត/១១១២/៩៦១

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្ដម **ផែន សុវិជ្ជានោ** ជាអនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ២:** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

៣៣ហ.១២១១.៩៧១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២

លេខ ៦១៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១២
**អគ្គលេខាធិការរងទីស្ដីការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១២/៩៦២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងលោកជំទាវ **ឌុច សុគន្ធ** ជាអនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា ២:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

[illegible].១២១១.៩៧២

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២*

លេខៈ៩១៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១២
**អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១២/៩៦៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

**ប្រោសព្រះរាជទាន**

ចំពោះ

នាយទាហាន នៃកងទ័ពប្រជាជនវៀតណាម ចំនួន ០២រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការពង្រឹងទំនាក់ទំនង អភិវឌ្ឍន៍ រវាងការិយាល័យទី៣ បញ្ជាការដ្ឋានកងទ័ពជើងគោក និងកងទ័ពប្រជាជនវៀតណាម ទទួលបានលទ្ធផលល្អប្រសើរ នូវ

**គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា**

១-វរសេនីយ៍ឯក NGUYEN ANH YUNG
២-វរសេនីយ៍ឯក DINH VAN PHOUNG

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៦-១២១១.៩៧៥

លេខៈ ៩៤៤ ច.ល

**ដើម្បីចម្លងចែក**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០១២*

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០១២

**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៩៣ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៩០៨ /១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០១ /១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែល ប្រកាសឲ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០៦ /៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- តាមសំណើ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- តាមសំណើ របស់ក្រសួងធនធានទឹក និងឧតុនិយម
- តាមសំណើ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សម្រេច

**មាត្រា ១ :-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវទីតាំងៈ

-សាខាប្រៃសណីយ៍ ក្រុងប៉ោយប៉ែត្រ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ស្ថិតនៅភូមិក្បាលស្ពាន សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលមានផ្ទៃដីទំហំ ១.៦២៨ ម៉ែត្រក្រឡា។

-នាយកដ្ឋានចំនួន ០៤ របស់ក្រសួងធនធានទឹក និងឧតុនិយម ស្ថិតនៅសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដែលមានផ្ទៃដីទំហំ ៤៤.៤៥៦ ម៉ែត្រក្រឡា។

-មជ្ឈមណ្ឌលទទួល និងផ្តល់សេវាជូនមនុស្សចាស់ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ស្ថិតនៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដែលមានផ្ទៃដីទំហំ ៥.៦៩២ ម៉ែត្រក្រឡា។

**មាត្រា ២ :-**

ការលប់ទីតាំងដូចមានចែងក្នុងមាត្រា ១ ចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីដោយ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ៣ :-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ...... ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៩៤ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពីការបង្កើតអនុគណៈកម្មការទទួលភារកិច្ចរៀបចំព្រះរាជពិធីបុណ្យព្រះបរមសព ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ

គណៈកម្មាធិការជាតិរៀបចំព្រះរាជពិធីបុណ្យព្រះបរមសព ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/១៦៥ ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០០៤ ស្តីពីការតែងតាំង **សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឧ្ករ គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ នឹងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១០១២/៩៤៦ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំព្រះរាជពិធីបុណ្យព្រះបរមសព **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ**
- យោង សំណូមពរការងារ និងតម្រូវការចាំបាច់។

## ស ម្រេ ច

**មាត្រា ១ :** -បង្កើតអនុគណៈកម្មការ ជាជំនួយការទទួលបន្ទុកអនុវត្តការងាររបស់គណៈកម្មាធិការជាតិរៀបចំព្រះរាជពិធីបុណ្យព្រះបរមសព **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិ** មានសមាសភាពដូចខាងក្រោម :

## ក/-អនុគណៈកម្មការស្ថាបនាព្រះបរមមេរុ ព្រះរាជរថសម្រាប់ដង្ហែ ទឹក អគ្គីសនី ភ្លើង និងលេខាធិការដ្ឋាន

១- សម្តេចចៅហ្វាវាំង គង់ សំអុល ប្រធាន
២- ឯកឧត្តម ខៀវ ឆាញ់ អនុប្រធាន
៣- ឯកឧត្តម គុយ សុផល អនុប្រធាន
៤- ឯកឧត្តម ជុំ ខៀន អនុប្រធាន
៥- ឯកឧត្តម ឈា ហាន អនុប្រធាន
៦- ឯកឧត្តម ជា គាន អនុប្រធាន
៧- ឯកឧត្តម ឃីម សារិទ្ធ អនុប្រធាន
៨- ឯកឧត្តម អ៊ុក សុជាតិ អនុប្រធាន
៩- អ្នកឧកញ៉ាភក្តីព្រះស្តេច ហេង គឹមគុណ សមាជិក
១០- អ្នកឧកញ៉ាសុធម្មប្រិជា នូ ទ៉ាន់ សមាជិក
១១- ព្រះជយាធិបតី ភង ភេន សមាជិក
១២- ឯកឧត្តម អន ស៊ាម សមាជិក
១៣- ឯកឧត្តម ឈិន កេតនា សមាជិក
១៤- ឯកឧត្តម ឥត សារ៉ាត់ សមាជិក
១៥- ឯកឧត្តម ម៉ៅ ហាវណ្ណាល់ សមាជិក
១៦- លោកជំទាវ គង់ បញ្ញា សមាជិកា
១៧- ឯកឧត្តម សួ ស៊ីនួន សមាជិក
១៨- ឯកឧត្តម គឹម សៀ សមាជិក
១៩- ឯកឧត្តម ឆាំ សុជាតិវង្ស សមាជិកា
២០- ឯកឧត្តម អ៊ុនដេង ពុធវិសាល សមាជិក
២១- ឯកឧត្តម ទ៉ាន់ ទ៉ាន សមាជិក
២២- ឯកឧត្តម មាស វ៉េន សមាជិក
២៣- ឯកឧត្តម អ៊ុក សារឹម សមាជិក
២៤- ឯកឧត្តម កែវ រតនៈ សមាជិក
២៥- ឯកឧត្តម ព្រាំ ពិសុទ្ធ សមាជិក
២៦- ឯកឧត្តម អ៊ុត រឿន សមាជិក
២៧- ឯកឧត្តម យី ឆន់ សមាជិក
២៨- លោកជំទាវ តាន់ សុខា សមាជិកា
២៩- ឯកឧត្តម ឡាក់ គី សមាជិក
៣០- ឯកឧត្តម ម៉ែន ទុទ្ធី សមាជិក
៣១- លោកជំទាវ សូ គន្ធកុសល សមាជិកា
៣២- ឯកឧត្តម នួន វណ្ណៈ សមាជិក
៣៣- ឯកឧត្តម ភុល ប៊ុនលី សមាជិក
៣៤- ឯកឧត្តម ខួន ពៅពង្ស សមាជិក
៣៥- ឯកឧត្តម ភង ស៊ីរីសោភ័ណ សមាជិក
៣៦- ឯកឧត្តម មូល សារឿន សមាជិក
៣៧- ឯកឧត្តម ផេង ភិរុណ សមាជិក
៣៨- ឯកឧត្តម ឆាន ណារុន សមាជិក
៣៩- ឯកឧត្តម ឆេង ហួត សមាជិក
៤០- លោក កើត ឆែ សមាជិក
៤១- លោក សុខ សម្បត្តិ សមាជិក
៤២- លោក អេង នាង សមាជិក
៤៣- លោក ស៊ឹម ស៊ីថា សមាជិក

អនុគណៈកម្មការនេះ មានភារកិច្ច :

- រៀបចំតម្កើងព្រះបរមមេរុ នៅទីតាំងវាលព្រះមេរុ ឱ្យបានទាន់ពេលវេលា ដោយត្រូវរៀបចំឱ្យបានស្របទៅនឹងព្រះរាជប្បវេណី រក្សារចនាបថខ្មែរ មានសោភណភាពប្រណីត។
- រៀបចំព្រះរាជរថ តាមចំនួនកំណត់ សម្រាប់បម្រើព្រះរាជពិធីដង្ហែព្រះបរមសព
- រៀបចំព្រះពន្លា វេទិកា និងរោងមហាជន តុបតែងលម្អតាមតម្រូវការចាំបាច់
- រៀបចំក្បួនដង្ហែព្រះបរមសព ប្លង់ដង្ហែ តាមមហាវិថីនានាឆ្លងកាត់ រូបភាពចាត់តាំងក្បួន តាមព្រះរាជប្បវេណី
- ផ្តល់អគ្គិសនី ឱ្យបានគ្រប់គ្រាន់ និងមានស្ថេរភាពបម្រើព្រះរាជពិធី

- សម្រួល ការងារប្រគេន-ជូនព្រះសង្ឃ គ្រហស្ថ ពីគ្រប់មជ្ឈដ្ឋាន ដែលមានសំណូមពរចូលគោរពព្រះបរមសព នៅក្នុងព្រះបរមរាជវាំង ឬនៅមុខព្រះបរមរាជវាំង ។
-ទទួលបន្ទុកកិច្ចការរដ្ឋបាលទូទៅ ទំនាក់ទំនងបណ្តាក្រសួង ស្ថាប័ន រាជធានី ខេត្ត បណ្តាអង្គការ ក្រៅរដ្ឋាភិបាល
- បោះពុម្ពលិខិតស្នាម ស្លាកសញ្ញាផ្សេងៗ តាមតម្រូវការ
- ដោះស្រាយរាល់ការងារចាំបាច់បន្ទាន់ជាក់ស្តែង ដែលអនុគណៈកម្មការនីមួយៗ មានសំណូមពរ
- ទទួលសំណូមពរពីគ្រប់ក្រសួង ស្ថាប័ន អង្គភាព រាជធានី ខេត្ត និងគ្រប់វត្តអារាមពិនិត្យ ដោះស្រាយ និងដាក់សុំយោបល់សម្រេច **សម្តេចអគ្គមហាសេនាបតីតេជោ** អនុប្រធានប្រចាំការ ។

**ខ/- <u>អនុគណៈកម្មការការពារសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម ចរាចរ និងសង្គ្រោះបន្ទាន់</u>**

| | | | | | |
|---|---|---|---|---|---|
| ១- ឯកឧត្តម | **ស ខេង** | ប្រធាន | ១១- ឯកឧត្តម | **ម៉ៅ ចន្ទរ៉ា** | សមាជិក |
| ២- ឯកឧត្តម | **នៀ ចាញ់** | អនុប្រធាន | ១២- ឯកឧត្តម | **យូ ស៊ុនឡុង** | សមាជិក |
| ៣- ឯកឧត្តម | **កែ គឹមយ៉ាន** | អនុប្រធាន | ១៣- ឯកឧត្តម | **ឥត សារ៉ាត** | សមាជិក |
| ៤- ឯកឧត្តម | **ឱម យិនទៀង** | អនុប្រធាន | ១៤- ឯកឧត្តម | **នៀ ទិញ** | សមាជិក |
| ៥- ឯកឧត្តម | **ម៉ម ប៊ុនហេង** | អនុប្រធាន | ១៥- ឯកឧត្តម | **ព្រហ្ម ឌិន** | សមាជិក |
| ៦- ឯកឧត្តម | **ប៉ុល សារឿន** | អនុប្រធាន | ១៦- ឯកឧត្តម | **ឃួង ស្រេង** | សមាជិក |
| ៧- ឯកឧត្តម | **តែ គុយស៊ាង** | សមាជិក | ១៧- ឯកឧត្តម | **ជួន សុវណ្ណ** | សមាជិក |
| ៨- ឯកឧត្តម | **កែប ជុតិមា** | សមាជិក | ១៨- ឯកឧត្តម | **យ៉ា គឹមអ៊ី** | សមាជិក |
| ៩- ឯកឧត្តម | **សៅ សុខា** | សមាជិក | ១៩- ឯកឧត្តម | **ឡូច ណារុទ** | សមាជិក |
| ១០- ឯកឧត្តម | **នេត សាវឿន** | សមាជិក | ២០- លោក | **ម៉ុក សុធី** | សមាជិក |

អនុគណៈកម្មការនេះ មានភារកិច្ច ៖

-រក្សាការពារសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម ចរាចរ សុខមាលភាព ឱ្យធានាសុវត្ថិភាពគ្រប់គ្រាន់ មុន-ក្រោយ និងក្នុងពេលប្រារព្ធព្រះរាជពិធីបុណ្យព្រះបរមសព រហូតដល់ថ្ងៃបញ្ចប់ព្រះរាជពិធីថ្វាយព្រះភ្លើង និងដង្ហែព្រះបរមអដ្ឋិទៅតម្កល់ក្នុងព្រះបរមចេតិយ ក្នុងព្រះបរមរាជវាំង ។

-ត្រៀមលក្ខណៈចាត់តាំងគ្រូពេទ្យ ថ្នាំពេទ្យ និងរថយន្តសង្គ្រោះ សម្រាប់ជួយសង្គ្រោះមហាជន ប្រជាជនដែលមកចូលរួមព្រះរាជពិធីបុណ្យព្រះបរមសពរៀងរាល់ថ្ងៃ ដែលមានសុខភាពមិនប្រក្រតី និងក្នុងព្រះរាជពិធីដង្ហែ តម្កល់ និងថ្វាយ ព្រះភ្លើង តាមទីតាំងជាក់ស្តែង ។

-ត្រៀមលក្ខណៈជ្រើសរើសមន្ទីរពេទ្យមួយចំនួន សម្រាប់ទទួលបងប្អូនអ្នកចូលរួម ដែលមានគ្រោះថ្នាក់ជាយថា-ហេតុដោយប្រការណាមួយ ។

-គ្រប់គ្រង រក្សាការពារក្បួនដង្ហែព្រះបរមសព និងព្រះរាជពិធីថ្វាយព្រះភ្លើង តាមវិថីឆ្លងកាត់ និងទីតាំងកំណត់ ។

-រៀបចំការបាញ់កាំភ្លើង និងបាញ់កាំជ្រួច នៅពេលថ្វាយព្រះភ្លើងព្រះបរមសព តាមកម្មវិធីកំណត់ ។

**គ/- អនុគណៈកម្មការពតិមាន ផ្សព្វផ្សាយ និងសាងសង់ព្រះបរមរូប**

| | | | | | |
|---|---|---|---|---|---|
| ១- ឯកឧត្តម | **សុខ អាន** | ប្រធាន | ៩- ឯកឧត្តម | **ថាច់ ផែន** | សមាជិក |
| ២- ឯកឧត្តម | **ម៉ិន ឈិន** | អនុប្រធាន | ១០- ឯកឧត្តម | **ម៉ៅ អាយុទ្ធ** | សមាជិក |
| ៣- ឯកឧត្តម | **អ៊ឹម ឈុនលឹម** | អនុប្រធាន | ១១- ឯកឧត្តម | **កែប ជុតិមា** | សមាជិក |
| ៤- ឯកឧត្តម | **ខៀវ ឃិនទៀង** | អនុប្រធាន | ១២- ឯកឧត្តម | **គីម គុណវឌ្ឍន៍** | សមាជិក |
| ៥- ឯកឧត្តម | **ហ៊ឹម ឆែម** | សមាជិក | ១៣- លោកជំទាវ | **ហ៊ុន ម៉ាណា** | សមាជិកា |
| ៦- ឯកឧត្តម | **ខៀវ កាញារីទ្ធ** | សមាជិក | ១៤- ឯកឧត្តម | **តន់ យ៉ាន** | សមាជិក |
| ៧- ឯកឧត្តម | **ឡុង ទិសាលោ** | សមាជិក | ១៥- ឯកឧត្តម | **ទ៉ែន ប៊ូរី** | សមាជិក |
| ៨- ឯកឧត្តម | **ស្វាយ ស៊ីថា** | សមាជិក | ១៦- ឯកឧត្តម | **ទិត សុធា** | សមាជិក |

អនុគណៈកម្មការនេះ មានភារកិច្ច :

-ស្រាវជ្រាវព្រះរាជជីវប្រវត្តិរបស់ព្រះបរមសព ពាក់ព័ន្ធនឹងព្រះរាជសកម្មភាពរបស់ព្រះអង្គក្នុងប្រទេស និងក្រៅប្រទេស

-ធ្វើការបោះពុម្ពជាសៀវភៅច្រើនច្បាប់ ច្រើនប្រភេទ សម្រាប់ផ្សព្វផ្សាយទូលំទូលាយ

-ធ្វើការផ្សព្វផ្សាយពតិមាន រូបភាពតាមវិទ្យុ ទូរទស្សន៍ជាតិ និងឯកជន ឱ្យបានញឹកញាប់

-ព្រះរាជវិយោគកថា និងឯកសារពាក់ព័ន្ធព្រះរាជពិធីបុណ្យ

-រថយន្តមីក្រូ ឧគ្ឃោសនស័ព្ទ សម្រាប់ព្រះរាជពិធីតាមតម្រូវការ

-ស្រាវជ្រាវ និងកសាងព្រះបរមរូប **ព្រះករុណាព្រះមហាវីរក្សត្រ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ** នៅទីតាំងសក្តិសមណាមួយ លើសួនច្បារចន្លោះវិមានឯករាជ្យ និងនាគបាញ់ទឹក តាមការកំណត់។

**ឃ/- អនុគណៈកម្មការបដិសណ្ឋារកិច្ច និងពិធីការ**

| | | | | | |
|---|---|---|---|---|---|
| ១- ឯកឧត្តម | **ហោ ណាំបុរ** | ប្រធាន | ១០- ឯកឧត្តម | **ហ៊ឹម សុធារិទ្ធ** | សមាជិក |
| ២- ឯកឧត្តម | **ឡុង ទិសាលោ** | អនុប្រធាន | ១១- ឯកឧត្តម | **ម៉ុត រមៀ** | សមាជិក |
| ៣- ឯកឧត្តម | **ម៉ៅ ហាវណ្ណាល់** | អនុប្រធាន | ១២- ឯកឧត្តម | **ព្រហ្ម វីរៈ** | សមាជិក |
| ៤- ឯកឧត្តម | **ណូ សម្បូរ** | អនុប្រធាន | ១៣- លោក | **ប្រាក់ ខូចបុរ** | សមាជិក |
| ៥- ឯកឧត្តម | **ទ៉ាន់ ទ៉ាន** | សមាជិក | ១៤- លោក | **ជួន សុខធី** | សមាជិក |
| ៦- ឯកឧត្តម | **ទេស ហេង** | សមាជិក | ១៥- លោក | **កើត ឆែ** | សមាជិក |
| ៧- ឯកឧត្តម | **រស់ គង់** | សមាជិក | ១៦- លោក | **អន នាង** | សមាជិក |
| ៨- ឯកឧត្តម | **ម៉ៅញ សំអាត** | សមាជិក | ១៧- លោក | **ហង្ស សុគន្ធក្រ** | សមាជិក |
| ៩- ឯកឧត្តម | **អ៊ុក សារឹម** | សមាជិក | | | |

អនុគណៈកម្មការនេះ មានភារកិច្ច :

-ធ្វើបដិសណ្ឋារកិច្ចទទួលភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ ដែលត្រូវចូលរួមឱ្យបានសក្តិសម

-ទទួលបន្ទុកធ្វើលិខិតស្នាមផ្សេងៗ ទាក់ទងជាមួយបណ្តាប្រទេស បណ្តាស្ថានទូត និងអង្គការអន្តរជាតិនានា។

-រៀបចំព្រះរាជពិធីថ្វាយព្រះរាជវន្ទនកិច្ច គោរពព្រះបរមសព

-រៀបចំអាសនៈ ទីតាំងឈរ គង់ អង្គុយ សម្រាប់ព្រះសង្ឃ គ្រហស្ថ ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ ក្នុងឱកាសដង្ហែ និងប្រារព្ធព្រះរាជពិធីថ្វាយព្រះភ្លើង។

- អញ្ជើញភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ ចូលរួមតាមចំនួនកំណត់។

**ង/- អនុគណៈកម្មការពិធីការសាសនា ព្រះរាជប្រពៃណី និងព្រះរាជពិធីថ្វាយព្រះភ្លើង**

| | | | | | |
|---|---|---|---|---|---|
| ១- លោកជំទាវ | **ម៉ែន សំអន** | ប្រធាន | ៧- ឯកឧត្តម | **ឡៅម ទាំលី** | សមាជិក |
| ២- ឯកឧត្តម | **ញឹក ប៊ុនឆៃ** | អនុប្រធាន | ៨- អ្នកឧកញ៉ាសុធម្មប្រីជា | **នូ ទាំន់** | សមាជិក |
| ៣- ឯកឧត្តម | **មិន ឃិន** | អនុប្រធាន | ៩- ឯកឧត្តម | **ទាំង ទាន់** | សមាជិក |
| ៤- ឯកឧត្តម | **ជា គាន** | អនុប្រធាន | ១០- ឯកឧត្តម | **ឃី ធន់** | សមាជិក |
| ៥- អ្នកឧកញ៉ាភក្តីព្រះស្តេច | **ហេង គឹមគុណ** | អនុប្រធាន | ១១- ព្រះជយាធិបតី | **កង កេន** | សមាជិក |
| ៦- ឯកឧត្តម | **ឃឹម សារិទ្ធ** | សមាជិក | ១២- ឯកឧត្តម | **គឹម សុន** | សមាជិក |

អនុគណៈកម្មការនេះ មានភារកិច្ច ៖

-ធ្វើកម្មវិធីលម្អិត សម្រាប់បម្រើការរៀបចំព្រះរាជពិធី ដង្ហែព្រះបរមសព និងថ្វាយព្រះភ្លើង

-រៀបចំព្រះរាជពិធីប្រចាំថ្ងៃ តាមកម្មវិធីកំណត់ ព្រឹក ល្ងាច យប់

-ទំនាក់ទំនងក្នុងការនិមន្តព្រះសង្ឃ តាមវត្ត តាមនិកាយ តាមចំនួនកំណត់ ចូលរួមទទួលភត្ត បង្សុកូល ចម្រើនព្រះបរិត្ត ទេសនា សូត្រព្រះធម្ម។

-ត្រៀមលក្ខណៈរៀបចំទេយ្យទាន សម្ភារៈ បរិក្ខារ សម្រាប់បម្រើកិច្ចការសាសនា តាមតម្រូវការ

-ត្រៀមលក្ខណៈរៀបចំព្រះរាជពិធីតម្កល់ព្រះបរមសព នៅលើព្រះបរមមេរុ តាមពេលវេលាកំណត់ សម្រាប់បម្រើព្រះរាជពិធីថ្វាយព្រះភ្លើងឱ្យបានស្របតាមព្រះរាជប្បវេណីជាតិ និងប្រពៃណីសាសនា

-ត្រៀមលក្ខណៈរៀបចំព្រះរាជពិធីដង្ហែ និងតម្កល់ព្រះបរមអដ្ឋិ ក្រោយពេលថ្វាយព្រះភ្លើង

**ច/- អនុគណៈកម្មការគ្រប់គ្រងហិរញ្ញវត្ថុ និងជីវភាព**

| | | | | | |
|---|---|---|---|---|---|
| ១- ឯកឧត្តម | **គាត ឈន់** | ប្រធាន | ៦- ឯកឧត្តម | **គឹម សឿ** | អនុប្រធាន |
| ២- ឯកឧត្តម | **ប៊ុន សម** | អនុប្រធាន | ៧- ឯកឧត្តម | **ម៉ែន ឧត្តី** | សមាជិក |
| ៣- ឯកឧត្តម | **ជា គាន** | អនុប្រធាន | ៨- លោក | **ណែត តឿត** | សមាជិក |
| ៤- ឯកឧត្តម | **ឈិន កេតនា** | អនុប្រធាន | ៩- លោក | **ខុន សុធន** | សមាជិក |
| ៥- ឯកឧត្តម | **ប៊ូន លឹមហេង** | អនុប្រធាន | ១០- លោក | **ប៊ុន សើរ** | សមាជិក |

អនុគណៈកម្មការនេះ មានភារកិច្ច ៖

-ដោះស្រាយសម្ភារៈ ថវិកា បម្រើការរៀបចំព្រះរាជពិធីបុណ្យព្រះបរមសព ចាប់ពីថ្ងៃសោយព្រះទិវង្គតរហូតដល់ថ្ងៃដង្ហែ និងតម្កល់ព្រះបរមអដ្ឋិ។

-គ្រប់គ្រង និងប្រើប្រាស់សម្ភារៈ ថវិកាឱ្យបានឆ្លើយតបទៅនឹងតម្រូវការចាំបាច់ជាក់ស្តែង នៃការរៀបចំព្រះរាជពិធីបុណ្យព្រះបរមសព ឱ្យបានសក្តិសម។

-ទទួលនិងគ្រប់គ្រងសម្ភារៈ បរិក្ខារ និងបច្ច័យ ដែលព្រះសង្ឃ គ្រហស្ថ បូជាឧទ្ទិសថ្វាយព្រះរាជកុសលព្រះបរមសព

-បូកសរុបចំណូលចំណាយ រាយការណ៍ជូនសម្តេចអនុប្រធានគណៈកម្មាធិការប្រចាំការ ឱ្យបានទៀងទាត់។

-លើកគម្រោងសម្ភារៈ ថវិកា ដែលត្រូវចំណាយបម្រើការរៀបចំព្រះរាជពិធី ដើម្បីសុំយោបល់សម្រេចពីគណៈ-កម្មាធិការជាតិរៀបចំព្រះរាជពិធីព្រះបរមសព។

**ឆ/- <u>អនុគណៈកម្មការគ្រប់គ្រង ព្រះសង្ឃ គ្រហស្ថ មហាជន ប្រជាជន</u>**

| | | | | | |
|---|---|---|---|---|---|
| ១- ឯកឧត្តម | **យឹម នៃលី** | ប្រធាន | ១៦- ឯកឧត្តម | **អ៊ុច អឿន** | សមាជិក |
| ២- ឯកឧត្តម | **មិន ឃិន** | អនុប្រធាន | ១៧- ឯកឧត្តម | **ស្បោង សារ៉ាត** | សមាជិក |
| ៣- ឯកឧត្តម | **អ៊ឹម សិទ្ធី** | អនុប្រធាន | ១៨- ឯកឧត្តម | **កែន សត្ថា** | សមាជិក |
| ៤- ឯកឧត្តម | **សក់ សេដ្ឋា** | អនុប្រធាន | ១៩- ឯកឧត្តម | **អ៊ី ឈាន** | សមាជិក |
| ៥- ឯកឧត្តម | **កែប ជុតិមា** | អនុប្រធាន | ២០- ឯកឧត្តម | **ស្រី បេន** | សមាជិក |
| ៦- ឯកឧត្តម | **ញៀម វ៉ាលី** | សមាជិក | ២១- ឯកឧត្តម | **ម៉ិន ឈើត** | សមាជិក |
| ៧- ឯកឧត្តម | **ជា អឿង** | សមាជិក | ២២- ឯកឧត្តម | **ខូយ ឃុនហួរ** | សមាជិក |
| ៨- ឯកឧត្តម | **ឈុន សិរុន** | សមាជិក | ២៣- ឯកឧត្តម | **ឈុន ឈន់** | សមាជិក |
| ៩- ឯកឧត្តម | **ហ៊ុន ណេង** | សមាជិក | ២៤- ឯកឧត្តម | **ម៉ិច សុខិន** | សមាជិក |
| ១០- ឯកឧត្តម | **ភង ហ៊ាង** | សមាជិក | ២៥- ឯកឧត្តម | **ស៊ូ គិរិន្ទ** | សមាជិក |
| ១១- ឯកឧត្តម | **ឌូច ម៉ារីម** | សមាជិក | ២៦- ឯកឧត្តម | **អ៊ុំ ម៉ារ៉ា** | សមាជិក |
| ១២- ឯកឧត្តម | **ឌៀង អំ** | សមាជិក | ២៧- ឯកឧត្តម | **ឡូយ សុផាត** | សមាជិក |
| ១៣- ឯកឧត្តម | **ហាស សារ៉េត** | សមាជិក | ២៨- ឯកឧត្តម | **ឆាំង ហមផាន** | សមាជិក |
| ១៤- ឯកឧត្តម | **ខូយ សុខា** | សមាជិក | ២៩- ឯកឧត្តម | **ចាន់ យឿន** | សមាជិក |
| ១៥- ឯកឧត្តម | **ប្រាជ្ញ ចន្ទ** | សមាជិក | ៣០- ឯកឧត្តម | **សរ ចំរុង** | សមាជិក |

អនុគណៈកម្មការនេះ មានភារកិច្ច :

-និមន្ត អញ្ជើញ ព្រះសង្ឃ គ្រហស្ថ មន្ត្រីរាជការ អ្នកមុខ អ្នកការ សិស្ស និស្សិត រាជធានី និងខេត្ត ដែលត្រូវចូលរួមក្នុងព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើងព្រះបរមសពតាមចំនួនកំណត់។

-គ្រប់គ្រងព្រះសង្ឃ គ្រហស្ថ មន្ត្រីរាជការ សិស្ស និស្សិត ដែលត្រូវនិមន្ត អញ្ជើញចូលរួមក្នុងព្រះរាជពិធីបុណ្យថ្វាយព្រះបរបសព ឱ្យបានគត់មត់ ច្បាស់លាស់ ដោយត្រូវទំនាក់ទំនងវត្តអារាម កន្លែងស្នាក់នៅ ចង្ហាន់សម្រាប់ព្រះសង្ឃតាមចំនួនកំណត់ជាក់ស្តែង។

-ចាត់តាំងឱ្យមានគណៈកម្មការមួយថ្នាក់រាជធានី ខេត្ត ដើម្បីទទួលខុសត្រូវ និងគ្រប់គ្រង ដឹកនាំព្រះសង្ឃ គ្រហស្ថ មន្ត្រីរាជការ សិស្ស និស្សិត ដែលត្រូវចូលរួមព្រះរាជពិធីបុណ្យព្រះបរមសព។

**មាត្រា ២** :-អនុគណៈកម្មការនីមួយៗ មានសិទ្ធិបង្កើតក្រុមការងារជំនាញ តាមតម្រូវការចាំបាច់ និងប្រើប្រាស់ត្រារបស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ក្នុងការងារលិខិតស្នាមរដ្ឋបាលទូទៅ។

**មាត្រា ៣** :-ការចំណាយលើការងារផ្សេងៗរបស់អនុគណៈកម្មការនីមួយៗ ត្រូវឆ្លងកាត់អនុគណៈកម្មការហិរញ្ញវត្ថុ និង **សម្តេចចៅហ្វាវាំង គង់ សំអុល** អនុប្រធានអចិន្ត្រៃយ៍ ពិនិត្យ និងសម្រេចដោយប្រើប្រាស់ត្រាក្រសួងព្រះបរមរាជវាំង។ ក្នុងករណីមិនអាចសម្រេចបាន ត្រូវស្នើសូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អនុប្រធានប្រចាំការ ពិនិត្យ និងសម្រេច។

**មាត្រា ៤** :-លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិរៀបចំព្រះរាជពិធីបុណ្យព្រះបរមសព ស្ថិតនៅគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ក្នុងបរិវេណពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត វិថីឧកញ៉ាឈុន កែងតិវិថីព្រះស៊ីសុវត្ថិ (អតីតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ)។

**មាត្រា ៥** :-អនុគណៈកម្មការនីមួយៗ ត្រូវបូកសរុបរាយការណ៍ ការងាយស្រួល ការលំបាក សំណូមពរ ជូន**សម្តេចចៅហ្វាវាំង** អនុប្រធានអចិន្ត្រៃយ៍ រៀងរាល់ថ្ងៃសុក្រ នៃសប្តាហ៍នីមួយៗ ដើម្បីពិនិត្យ ដោះស្រាយ និងផ្តល់យោបល់ ជូន**សម្តេចអគ្គមហាសេនាបតីតេជោ** ពិនិត្យ និងសម្រេច។

**មាត្រា ៦** :- ឯកឧត្តម លោកជំទាវ លោក លោកស្រី ដូចក្នុងប្រការមួយ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធិភាពខ្ពស់។

**មាត្រា ៧** :-អនុក្រឹត្យនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចម្លងជូន** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១៩៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការប្រែក្លាយមន្ទីរពេទ្យព្រះអង្គឌួងជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

មន្ទីរពេទ្យព្រះអង្គឌួង ដែលសរសេរជាអក្សរកាត់ថា **ម.ព.អ.ឌ.** ត្រូវបានសម្រេចឲ្យប្រែក្លាយទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសុខាភិបាល និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា ២.-**

**ម.ព.អ.ឌ.** ជានីតិបុគ្គលនិងមានស្វ័យភាពហិរញ្ញវត្ថុ។

**ម.ព.អ.ឌ.** មានអាសយដ្ឋានដីឡូត៍លេខ១១ កែងផ្លូវក្រមួនសនិងមហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មីទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

ការផ្លាស់ប្តូរអាសយដ្ឋាននៅពេលអនាគតជាសមត្ថកិច្ចរបស់ **ម.ព.អ.ឌ.**។

**មាត្រា ៣.-**

**ម.ព.អ.ឌ.** មានភារកិច្ចជាអាទិ៍ដូចតទៅ៖

- រ៉ាប់រងការពិនិត្យពោគវិនិច្ឆ័យ ព្យាបាលថែរក្សាអ្នកជំងឺឬអ្នករបួសផ្នែកភ្នែក ត្រចៀក ច្រមុះ បំពង់ក និងមាត់ធ្មេញ ដែលត្រូវបញ្ជូនឬបានសុំមកព្យាបាលក្នុងមន្ទីរពេទ្យនេះ ព្រមទាំងផ្តល់ទីសំណាក់ជូនដល់ជនខាងលើនេះតាមលទ្ធភាពរបស់មន្ទីរពេទ្យ។ ទៅអនាគត **ម.ព.អ.ឌ.** អាចពង្រីកការព្យាបាលជំងឺផ្សេងទៀតតាមការចាំបាច់
- ផ្តល់ការថែរក្សាព្យាបាលជំងឺស្រាលឬជំងឺធ្ងន់ទៅតាមឯកទេស
- ផ្តល់ជូនអ្នកជំងឺគ្រប់រូបនូវការពិនិត្យព្យាបាលតាមតម្រូវការ និងតាមលទ្ធភាពរបស់សាមីអង្គភាព
- ពិគ្រោះយោបល់និងព្យាបាលជំងឺដោយមិនមានការរើសអើង និងតាមកម្រិតបច្ចេកទេសដូចគ្នា ប៉ុន្តែអាចផ្តល់របបស្នាក់នៅកម្រិតខុសគ្នា អាស្រ័យតាមឆន្ទៈរបស់អ្នកជំងឺ ឬគ្រួសារអ្នកជំងឺ ឬអាស្រ័យតាមលទ្ធភាពថវិការបស់អ្នកជំងឺ ដោយអនុលោមតាមតម្លៃសេវាកម្មរបស់មន្ទីរពេទ្យ
- ធ្វើសហការក្នុងផ្នែកវេជ្ជសាស្ត្រ បង្ការការពារ និងផ្តល់សេវាសម្រាប់វេជ្ជសេវាកិច្ចអាសន្ន
- ចាត់វិធានការដើម្បីឆ្លើយតបនឹងការសង្គ្រោះបន្ទាន់ឬរ៉ាប់រងសម្រួលឲ្យអ្នកជំងឺទៅព្យាបាលនៅមន្ទីរពេទ្យដទៃទៀត
- ផ្តល់ឲ្យអ្នកជំងឺនូវការព្យាបាលរោគ ការបង្ការរោគ និងការសម្រាលរោគតាមស្តង់ដារបច្ចេកទេស

- ចាត់ចែងឲ្យបានល្អត្រឹមត្រូវនូវការព្យាបាលបន្ទាន់លើគ្រប់ផ្នែកនិងអាស្រ័យតាមមធ្យោបាយរបស់មន្ទីរពេទ្យ
- ចូលរួមបណ្តុះបណ្តាលនិងស្រាវជ្រាវវិស័យវេជ្ជសាស្ត្រ ទន្តសាស្ត្រ ឱសថសាស្ត្រព្រមទាំងជួយបណ្តុះបណ្តាលបុគ្គលិក
- ធ្វើសហការក្នុងផ្នែកព្យាបាល បង្ការការពារ និងអប់រំសុខភាព
- ធ្វើសហប្រតិបត្តិការនានាក្រោមការណែនាំពីក្រសួងសុខាភិបាល។

## ជំពូកទី២
## ការដឹកនាំនិងការគ្រប់គ្រង
## ផ្នែកទី១
## ក្រុមប្រឹក្សាភិបាលរបស់ ម.ព.អ.ឌ.

**មាត្រា ៤.-**

**ម.ព.អ.ឌ.** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលដែលមានសិទ្ធិទូលំទូលាយដើម្បីចាត់ចែងការងារក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិនៃអនុក្រឹត្យនេះនិងបទបញ្ជាផ្ទៃក្នុងរបស់ **ម.ព.អ.ឌ.**។

**មាត្រា ៥.-**

៥.១-ក្រុមប្រឹក្សាភិបាលមានសមាជិក ០៧(ប្រាំពីរ)រូប ដែលមានសមាសភាពដូចតទៅ៖

- តំណាងក្រសួងសុខាភិបាល ប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- ឥស្សរជនដែលមានចំណេះដឹងនិងបទពិសោធខាងវិទ្យាសាស្ត្រសុខាភិបាល សមាជិក
- តំណាងសាលារាជធានីភ្នំពេញ សមាជិក
- នាយកនៃ **ម.ព.អ.ឌ.** សមាជិកស្វ័យប្រវត្ត
- តំណាងបុគ្គលិកនៃ **ម.ព.អ.ឌ.** សមាជិកស្វ័យប្រវត្ត

៥.២-តំណាងបុគ្គលិកនៃ **ម.ព.អ.ឌ.** ត្រូវជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមបុគ្គលិក **ម.ព.អ.ឌ.** សម្រាប់អាណត្តិនីមួយៗ។

៥.៣-ប្រធាននិងសមាជិកក្រុមប្រឹក្សាភិបាលដែលមិនមែនជាសមាជិកស្វ័យប្រវត្ត ត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ៣(បី)ឆ្នាំ និងអាចបន្តបានទៀតតាមសំណើរបស់ក្រសួងឬស្ថាប័នដែលសមាជិកនោះជាតំណាង។

៥.៤-អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលាដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬស្ថាប័នដែលសមាជិកនោះជាតំណាង។

**មាត្រា ៦.-**

សមាជិកក្រុមប្រឹក្សាភិបាលត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបម្រើការងារយ៉ាងតិច០៥(ប្រាំ)ឆ្នាំ ឬជាឥស្សរជនដែលមានបទពិសោធគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រសុខាភិបាល អប់រំ ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងមានលិខិតថ្កោលទោសបញ្ជាក់ថាពុំដែលបានទទួលទណ្ឌកម្មជាបទមជ្ឈិមឬបទឧក្រិដ្ឋពីតុលាការឡើយ។

**មាត្រា ៧.-**

៧.១-ប្រធានក្រុមប្រឹក្សាភិបាលមានតួនាទីកោះប្រជុំនិងកំណត់របៀបវារៈនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល។

៧.២-ប្រធានក្រុមប្រឹក្សាភិបាលអាចអញ្ជើញឥស្សរជននៅក្រៅក្រុមប្រឹក្សាភិបាលដែលមានបទពិសោធលើវិស័យវិទ្យាសាស្ត្រសុខាភិបាល និងតំណាងដៃគូអភិវឌ្ឍឲ្យចូលរួមក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាលបាន។ ឥស្សរជនទាំងនោះមានសិទ្ធិផ្តល់មតិតែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ។

**មាត្រា ៨.-**

ក្រុមប្រឹក្សាភិបាលមានបេសកកម្មដឹកនាំ តម្រង់ទិស និងធ្វើការត្រួតពិនិត្យលើដំណើរការរបស់ **ម.ព.អ.ឧ.**។ ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលត្រូវ៖

- ពិនិត្យនិងសម្រេចលើគម្រោងផែនការអភិវឌ្ឍនៃ **ម.ព.អ.ឧ.** ស្របតាមទិសដៅកំណត់របស់រាជរដ្ឋាភិបាល
- ពិនិត្យនិងសម្រេចលើគម្រោងផែនការសកម្មភាពនៃ **ម.ព.អ.ឧ.**
- ពិនិត្យនិងសម្រេចលើចំណូលនិងចំណាយប្រចាំឆ្នាំ ព្រមទាំងទុនក្នុងថវិកាប្រចាំឆ្នាំរបស់ **ម.ព.អ.ឧ.**
- ពិនិត្យនិងសម្រេចលើរបាយការណ៍ស្តីពីការគ្រប់គ្រងនិងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ការរៀបចំរចនាសម្ព័ន្ធនិងការបែងចែកភារកិច្ចជាទូទៅដល់គ្រប់ការិយាល័យនិងអង្គភាពក្រោមឱវាទ និងធ្វើការអភិវឌ្ឍតាមការចាំបាច់របស់ **ម.ព.អ.ឧ.**
- កំណត់បែបបទនៃការជ្រើសរើស ការដំឡើងឋានន្តរសក្តិ ការផ្តល់លាភការដល់បុគ្គលិក **ម.ព.អ.ឧ.** ដោយមិនប៉ះពាល់ដល់បទប្បញ្ញត្តិច្បាប់ឬបទបញ្ជាផ្ទៃក្នុងដែលអនុវត្តចំពោះមន្ត្រីមុខងារសាធារណៈ
- សម្រេចលើក្របខ័ណ្ឌចំនួនបុគ្គលិកដែលអនុញ្ញាតសម្រាប់ **ម.ព.អ.ឧ.**
- សម្រេចលើកិច្ចសន្យាស្តីពីលទ្ធកម្មសាធាណៈដោយអនុវត្តតាមបទប្បញ្ញត្តិនៃលទ្ធកម្មសាធារណៈ

- កែសម្រួលបទបញ្ជាផ្ទៃក្នុងនៃ **ម.ពា.អ.ឌ.** ដោយមានការយល់ព្រមពីប្រធានស្ថាប័នឬក្រសួងអាណាព្យាបាលទាំងពីរ
- វាយតម្លៃតាមចន្លោះពេលទៀងទាត់ លើកម្រិតលទ្ធផលសម្រេចបានតាមគោលដៅកំណត់ដោយ **ម.ពា.អ.ឌ.** ហើយកំណត់វិធានការកែតម្រូវដើម្បីអនុវត្ត។

**មាត្រា ៩.-**

លាភការរបស់សមាជិកក្រុមប្រឹក្សាភិបាល ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ក្រោយពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា ១០.-**

១០.១-ក្រុមប្រឹក្សាភិបាលនៃ **ម.ពា.អ.ឌ.** ត្រូវធ្វើការប្រជុំយ៉ាងតិច៣(បី)ខែម្តង តាមគំនិតផ្តួចផ្តើម និងការអញ្ជើញរបស់ប្រធាន ឬតាមការស្នើរបស់សមាជិកចំនួន២/៣(ពីរភាគបី)ឡើងទៅ ឬតាមការស្នើសុំរបស់នាយកនៃ **ម.ពា.អ.ឌ.**។ ក្នុងករណីមានធុរៈ ប្រធានត្រូវផ្ទេរសិទ្ធិជូនសមាជិកណាម្នាក់ក្នុងចំណោមសមាជិករបស់ក្រុមប្រឹក្សាភិបាល ដើម្បីដឹកនាំការប្រជុំ។ ប្រធានអង្គប្រជុំត្រូវជ្រើសរើសលេខាធិការនៃអង្គប្រជុំ១(មួយ) រូបដែលមិនមែនជាសមាជិកក្រុមប្រឹក្សាភិបាល។ លេខាធិការនេះគ្មានសិទ្ធិបោះឆ្នោតទេ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវចូលរួមប្រជុំក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែគ្មានសិទ្ធិបោះឆ្នោតទេ។

របៀបវារៈព្រមទាំងឯកសារទាំងឡាយត្រូវផ្ញើជូនគ្រប់សមាជិកនៃក្រុមប្រឹក្សាភិបាលនិងក្រសួងស្ថាប័នពាក់ព័ន្ធដែលមានចែងក្នុងអនុក្រឹត្យនេះ យ៉ាងតិច១០(ដប់)ថ្ងៃមុនថ្ងៃប្រជុំ។

១០.២-ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានចំនួនសមាជិកលើសពី៥០(ហាសិប)ភាគរយ នៃចំនួនសមាជិកទាំងអស់។ សមាជិកអវត្តមានគ្មានសិទ្ធិបញ្ជូនតំណាងឲ្យមកប្រជុំជំនួសខ្លួនបានឡើយ។ ប្រសិនបើកូរ៉ុមមិនគ្រប់ចំនួនទេក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំម្តងទៀតយ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃក្រោយថ្ងៃប្រជុំលើកមុន ហើយការប្រជុំលើកក្រោយនេះមិនចាំបាច់តម្រូវមានកូរ៉ុមគ្រប់ចំនួនឡើយហើយត្រូវពិភាក្សាតែលើរបៀបវារៈនៃការអញ្ជើញប្រជុំលើកមុន។ សមាជិកវត្តមានត្រូវចុះហត្ថលេខាលើបញ្ជីវត្តមានមួយ។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំឡេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានអង្គប្រជុំចាត់ទុកជាឧត្តមានុភាព។

១០.៣-សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយតម្កល់ទុកនៅទីស្នាក់ការរបស់ **ម.ពា.អ.ឌ.** និងត្រូវបានចុះហត្ថលេខាដោយប្រធានក្រុមអង្គប្រជុំ និងលេខាធិការអង្គប្រជុំ។ កំណត់ហេតុនេះត្រូវបង្ហាញនូវអត្ថន័យនៃការពិភាក្សាឲ្យបានច្បាស់លាស់ និងត្រូវផ្ញើជូនគ្រប់សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងផ្ញើជូនក្រសួងពាក់ព័ន្ធយ៉ាងយូរ១០(ដប់)ថ្ងៃក្រោយពេលប្រជុំ។

១០.៤-**ម.ព.អ.ឧ.** ត្រូវផ្ញើជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នូវឯកសារដូចតទៅ៖

- កំណត់ហេតុនៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍរបស់ **ម.ព.អ.ឧ.**
- គម្រោងថវិកាប្រចាំឆ្នាំ
- របាយការណ៍ស្តីពីការគ្រប់គ្រងនិងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ។

១០.៥-ឯកសារទាំងនេះត្រូវបញ្ជូនទៅអ្នកដែលត្រូវទទួល ក្នុងរយៈពេលមិនហួសពី១៥(ដប់ប្រាំ)ថ្ងៃ។

## ផ្នែកទី២
## អង្គការប្រតិបត្តិរបស់ ម.ព.អ.ឧ.

### មាត្រា ១១.-

**ម.ព.អ.ឧ.** ត្រូវគ្រប់គ្រងដោយនាយកមន្ទីរពេទ្យមួយរូបដែលត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។ នាយកមន្ទីរពេទ្យរូបនេះមានតួនាទីជានាយកប្រតិបត្តិ។

### មាត្រា ១២.-

១២.១-នាយកនៃ **ម.ព.អ.ឧ.** មានសិទ្ធិពេញលេញដើម្បីគ្រប់គ្រងនិងអនុវត្តការងារដែលមានចែងក្នុងអនុក្រឹត្យនេះ លើកលែងតែកិច្ចការដែលជាសមត្ថកិច្ចផ្ទាល់របស់ក្រុមប្រឹក្សាភិបាល។

នាយកនៃ **ម.ព.អ.ឧ.** មានភារកិច្ច៖

- រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងដាក់ឲ្យដំណើរការនូវគោលនយោបាយដែលកំណត់ដោយក្រុមប្រឹក្សាភិបាលនេះ
- រៀបចំថវិកាប្រចាំឆ្នាំសម្រាប់ **ម.ព.អ.ឧ.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងសម្រេច
- ធ្វើរបាយការណ៍ការងារគ្រប់គ្រងប្រចាំឆ្នាំ ត្រួតពិនិត្យគណនីហិរញ្ញវត្ថុប្រចាំឆ្នាំនិងដាក់ឯកសារទាំងនេះជូនក្រុមប្រឹក្សាភិបាលពិនិត្យ
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ លើភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ
- បំពេញរាល់មុខតំណែងរបស់ **ម.ព.អ.ឧ.** ក្នុងការកម្រិតក្របខ័ណ្ឌចំនួនបុគ្គលិកដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ព្រមទាំងគោរពតាមវិធានការគ្រប់គ្រងបុគ្គលិក
- បំពេញតួនាទីតាមឋានានុក្រមចំពោះបុគ្គលិកទាំងអស់របស់ **ម.ព.អ.ឧ.** ដែលក្រុមប្រឹក្សាភិបាលកំណត់ តាមការបែងចែកសិទ្ធិអំណាចនិងតាមបទបញ្ជាផ្ទៃក្នុងព្រមទាំងបទប្បញ្ញត្តិដទៃទៀត។

១២.២-នាយកនៃ **ម.ព.អ.ឧ.** ជាតំណាងរបស់មន្ទីរពេទ្យក្នុងការទាក់ទងជាមួយតតិយជន។

១២.៣-នាយកនៃ **ម.ព.អ.ឧ.** ត្រូវស្នើទៅក្រសួងសុខាភិបាលសុំតែងតាំងនាយករងមួយរូប ឬច្រើនរូបជាជំនួយការតាមការចាំបាច់ ដោយមានការឯកភាពពីក្រុមប្រឹក្សាភិបាល។ នាយកនិងនាយករងត្រូវមានចំណេះដឹងលើផ្នែកគ្រប់គ្រង។

## ផ្នែកទី៣
## បុគ្គលិករបស់ ម.ព.អ.ឧ.

**មាត្រា ១៣.-**

១៣.១-បុគ្គលិកអចិន្ត្រៃយ៍របស់ **ម.ព.អ.ឧ.** មានមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ មកពីក្រសួងសុខាភិបាលឬមកពីក្រសួងស្ថាប័នរដ្ឋដទៃទៀត។ មន្ត្រីទាំងឡាយនេះត្រូវបានរក្សាទុកក្របខ័ណ្ឌ ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗ ដែលកំណត់ដោយមុខងារសាធារណៈពីអង្គភាពដើមរបស់ខ្លួន។

១៣.២-**ម.ព.អ.ឧ.** អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ជំនួយការ និងបុគ្គលិកអណ្តែត។ បុគ្គលិកទាំងនេះត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុងនិងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្របតាមច្បាប់ស្តីពីការងារ។

១៣.៣-បុគ្គលិក **ម.ព.អ.ឧ.** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាស្តីពីការគ្រប់គ្រងបុគ្គលិកដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។ ចំពោះមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ បទបញ្ជានេះមិនត្រូវផ្ទុយពីបទប្បញ្ញត្តិទាំងឡាយនៃច្បាប់និងអត្ថបទពាក់ព័ន្ធដទៃទៀតរបស់មន្ត្រីរាជការឡើយ។

ក្រុមប្រឹក្សាភិបាលត្រូវកំណត់ប្រាក់កម្រៃលើកទឹកចិត្តចំពោះបុគ្គលិក ព្រមទាំងបែបបទនៃការទូទាត់ផង ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង។

## ផ្នែកទី៤
## ទ្រព្យសម្បត្តិរបស់ ម.ព.អ.ឧ.

**មាត្រា ១៤.-**

១៤.១-**ម.ព.អ.ឧ.** ទទួលជាដើមទុនដំបូងពីរដ្ឋនូវដីធ្លីនិងអចលនវត្ថុដែលមានបញ្ជាក់ក្នុងតារាងឧបសម្ព័ន្ធតាមបញ្ជីសារពើភណ្ឌចុងក្រោយ ដែលផ្ទៃដីមានទំហំ៧ ៧២១(ប្រាំពីរពាន់ប្រាំពីររយម្ភៃមួយ)ម៉ែត្រការ៉េ ស្ថិតក្នុងដីឡូត៍លេខ១១ កែងផ្លូវក្រមួនសនិងមហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មីទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

១៤.២-**ម.ព.អ.ឧ.** អាចទិញ ប្តូរ ឬលក់ចលនទ្រព្យ អចលនទ្រព្យចាំបាច់សម្រាប់ដំណើរការមន្ទីរពេទ្យបាន ដោយមានការឯកភាពពីក្រសួងអាណាព្យាបាលទាំងពីរ និងស្របតាមច្បាប់ជាធរមាន។

## ផ្នែកទី៥
## ការគ្រប់គ្រងហិរញ្ញវត្ថុនិងគណនេយ្យរបស់ ម.ព.អ.ឧ.

**មាត្រា ១៥.-**

ការគ្រប់គ្រងហិរញ្ញវត្ថុនិងគណនេយ្យនៃ **ម.ព.អ.ឧ.** ត្រូវប្រព្រឹត្តស្របតាមគោលការណ៍នៃគណនេយ្យសាធារណៈ ដូចមានចែងនៅក្នុងមាត្រា១២២នៃអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ។

**មាត្រា ១៦.-**

១៦.១-នាយកមន្ទីរពេទ្យជាអាណាប័កដើមខ្សែរបស់មន្ទីរពេទ្យហើយត្រូវមានភារកិច្ចៈ

- ពិនិត្យប្រាក់និងទូទាត់ប្រាក់ចំណូល
- ចាត់ចែងធ្វើការទូទាត់និងចេញបញ្ជាចំណាយ។

១៦.២-អាណាប័កដើមខ្សែអាចផ្ទេរសិទ្ធិឲ្យអាណាប័កផ្ទេរសិទ្ធិឬអាចបង្កើតនូវរជ្ជទេយ្យចំណូល ឬបុរេប្រទានបាន ដោយមានការព្រមព្រៀងពីគណនេយ្យកររបស់ **ម.ព.អ.ឧ.**។

**មាត្រា ១៧.-**

១៧.១-ការគ្រប់គ្រងហិរញ្ញវត្ថុនិងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមទៅតាមបទបញ្ញាផ្ទៃក្នុងរបស់ **ម.ព.អ.ឧ.** ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ។ គណនេយ្យករត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់ការងារ។ គណនេយ្យករនេះត្រូវទទួលខុសត្រូវចំពោះមុខនាយក **ម.ព.អ.ឧ.** និងត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នកពិគ្រោះយោបល់ តែឥតមានសំឡេងឆ្នោតឡើយ។

១៧.២-គណនេយ្យករនេះមានភារកិច្ចដូចតទៅៈ

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ
- ថែរក្សានិងចាត់ចែងប្រើប្រាស់មូលនិធិ និងធនធានរបស់ **ម.ព.អ.ឧ.**
- រក្សាទុកនូវលិខិតយុត្តិការនិងកាន់កាប់បញ្ជីគណនេយ្យ។

១៧.៣-គណនេយ្យករអាចផ្តល់សិទ្ធិខ្លះទៅឲ្យអាជ្ញានុការីរបស់ខ្លួន។

**មាត្រា ១៨.-**

១៨.១-ប្រភពធនធានរបស់ **ម.ព.អ.ឧ.** រួមមានៈ

- ធនធានដំបូងរបស់រដ្ឋផ្តល់ដល់ **ម.ព.អ.ឧ.** នៅពេលចាប់ផ្តើមបង្កើតដំបូង
- ឧបត្ថម្ភធនសម្រាប់ដំណើរការនិងឧបត្ថម្ភធនជាមូលធនដែលមានចែងក្នុងថវិកាជាតិ
- អំណោយ ជំនួយ និងអច្ច័យទានដែល **ម.ព.អ.ឧ.** បានទទួល
- ប្រាក់ខ្ចីដោយផ្ទាល់និងប្រាក់ដែលរដ្ឋខ្ចីបុលឲ្យ **ម.ព.អ.ឧ.**

- ផលការងារនិងកម្រៃនៃការផ្តល់សេវាផ្សេងៗដោយ **ម.ព.អ.ឧ.**
- កម្រៃនៃទ្រព្យរបស់ **ម.ព.អ.ឧ.** និងចំណូលនៃការលក់ទ្រព្យសម្បត្តិ ដែលត្រូវបានទទួលអនុញ្ញាតពីរាជរដ្ឋាភិបាល
- កម្រៃនៃទ្រព្យសម្បត្តិដែលត្រូវបានប្រគល់ឲ្យ **ម.ព.អ.ឧ.**។

១៨.២-ចំណូលចំណាយជាប្រចាំព្រមទាំងមូលធនរបស់ **ម.ព.អ.ឧ.** ត្រូវបានគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់មន្ទីរពេទ្យ។ ក្រុមប្រឹក្សាភិបាលរបស់ **ម.ព.អ.ឧ.** ត្រូវកំណត់បែបបទនៃការរៀបចំចាត់ចែងនិងអនុវត្តថវិកា។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលទាក់ទងនឹងទម្រង់បែបបទនៃការរៀបចំចាត់ចែងនិងអនុវត្តថវិកា ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

១៨.៣-ថវិកាត្រូវរៀបចំដោយអាណាប័កដើមខ្សែ **ម.ព.អ.ឧ.** ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល ដែលត្រូវធ្វើការសម្រេចយ៉ាងយូរត្រឹមថ្ងៃទី៣០ ខែកញ្ញា ក្នុងឆ្នាំនីមួយៗ។ ថវិកាត្រូវធ្វើឲ្យមានលំនឹងរវាងចំណូលនិងចំណាយ។

១៨.៤-អនុលោមតាមមាត្រា១៣ខាងលើនេះប្រាក់បៀវត្សនិងប្រាក់កម្រៃផ្សេងៗ នៃមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈដែលមកបម្រើការងារក្នុង **ម.ព.អ.ឧ.** ជាបន្ទុកនៃថវិការដ្ឋ។

១៨.៥-ប្រាក់ឧបត្ថម្ភរបស់រដ្ឋដែលបានគ្រោងទុកក្នុងថវិកាជាតិដើម្បីផ្តល់ឲ្យ **ម.ព.អ.ឧ.** ត្រូវសំដៅជាពិសេសលើចំណាយថ្លៃទឹកនិងថ្លៃភ្លើង។

១៨.៦-សោហ៊ុយវិភាគនិងសោហ៊ុយដំណើរការ សម្រាប់ស្រាវជ្រាវវិភាគ សម្រាប់ពេលមានអាសន្ន ត្រូវចែងក្នុងកិច្ចសន្យាមួយរវាងរដ្ឋនិង **ម.ព.អ.ឧ.** ដែលមានបញ្ជាក់ចំណែកដែលភាគីម្ខាងៗត្រូវរ៉ាប់រង។

**មាត្រា ១៩.-**

១៩.១-ការងារគណនេយ្យរបស់ **ម.ព.អ.ឧ.** រួមមានៈ

- គណនេយ្យទូទៅត្រូវកាន់កាប់ជាគណនេយ្យទ្វេភាគដែលចែងអំពីប្រតិបត្តិការថវិការតនាគារនិងប្រតិបត្តិការដែលអនុវត្តជាមួយតតិយជន
- គណនេយ្យអសង្ហារិម រូបធាតុ និងគណនេយ្យតម្លៃ
- គណនេយ្យវិភាគ ប្រសិនបើជាការចាំបាច់។

គណនេយ្យរបស់ **ម.ព.អ.ឧ.** ត្រូវៈ

- ស្របតាមវិធានការដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គោរពតាមប្លង់គណនេយ្យរបស់ **ម.ព.អ.ឧ.** ដែលត្រូវបានសម្រេចដោយក្រុមប្រឹក្សាភិបាល។

ប្លង់គណនេយ្យនេះត្រូវបានយល់ព្រមដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

១៩.២-របាយការណ៍ស្តីពីការគ្រប់គ្រងនិងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ **ម.ព.អ.ឧ.** ត្រូវរៀបចំដោយគណនេយ្យករនិងអាណាប័កដើមខ្សែ ដោយភ្ជាប់ជាមួយនឹងរបាយការណ៍គ្រប់គ្រង។

ដើម្បីជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងសម្រេចលើឯកសារទាំងនេះយ៉ាងយូរ៣(បី)ខែ ក្រោយការបិទការិយបរិច្ឆេទគណនេយ្យ។

**មាត្រា ២០.-**

មូលនិធិរបស់ **ម.ព.អ.ឌ.** គឺជាមូលនិធិសាធារណៈដែលត្រូវដាក់ចូលក្នុងគណនីមួយ នៅអគ្គនាយកដ្ឋានរតនាគារជាតិជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិដែលត្រូវមានការយល់ព្រមតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៦
## របបសារពើពន្ធរបស់ ម.ព.អ.ឌ.

**មាត្រា ២១.-**

លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយច្បាប់ **ម.ព.អ.ឌ.** ត្រូវស្ថិតនៅក្រោមនីតិរូបចំពោះរបបសារពើពន្ធ។

## ផ្នែកទី៧
## លទ្ធកម្មរបស់ ម.ព.អ.ឌ.

**មាត្រា ២២.-**

ការសម្រេច ការអនុវត្ត និងការត្រួតពិនិត្យលើលទ្ធកម្មរបស់ **ម.ព.អ.ឌ.** ត្រូវគ្រប់គ្រងតាមច្បាប់និងបទបញ្ញាទាំងឡាយជាធរមានដែលពាក់ព័ន្ធនឹងកិច្ចការនេះ។

# ជំពូកទី៣
# អាណាព្យាបាលភាព
## ផ្នែកទី១
## អាណាព្យាបាលបច្ចេកទេស

**មាត្រា ២៣.-**

២៣.១-ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ក្រោយពេលប្រជុំក្រុមប្រឹក្សាភិបាល នាយកនៃ **ម.ព.អ.ឌ.** ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាលនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវកម្មវិធីអភិវឌ្ឍនិងគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីសុំការយល់ព្រម។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានរយៈពេល១(មួយ)ខែ ចាប់ពីថ្ងៃទទួលឯកសារ ដើម្បីរៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល។ រដ្ឋមន្ត្រីក្រសួងសុខាភិបាល មានរយៈពេល២(ពីរ)ខែ ចាប់ពីថ្ងៃទទួលឯកសារដែលបានបញ្ជូនដោយនាយកនៃ **ម.ព.អ.ឌ.** ដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារទាំងនេះ។

| | | 6021 | សម្ភារៈការិយាល័យនិងការបោះពុម្ព | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6022 | សៀវភៅមើលនិងឯកសារ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6028 | ផ្សេងៗ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 603 | | ស្បៀងអាហារ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6031 | ស្បៀង | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 604 | | សំលៀកបំពាក់និងការតុបតែង | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6041 | ឯកសណ្ឋាន | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6042 | សំលៀកបំពាក់ការពារសុវត្ថិភាព | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6043 | មេដាយ(គ្រឿងឥស្សរិយយស) | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6048 | ផ្សេងៗ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 605 | | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6051 | សម្ភារៈនិងបរិក្ខារ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6052 | សង្ហារឹម | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6053 | សម្ភារៈប្រើប្រាស់ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6054 | សម្ភារៈនិងឧបករណ៍ដឹកជញ្ជូន | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6058 | ផ្សេងៗ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 606 | | ថាមពលនិងទឹក | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6061 | អគ្គិសនី | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6062 | ទឹក | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6068 | ផ្សេងៗ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 608 | | សម្ភារៈផ្គត់ផ្គង់ផ្សេងៗ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| 61 | សេវាខាងក្រៅ | | | | | |
| | 611 | | កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស | ឥណពន្ធ | ឥណទាន | ឥណាយិក |

| | | | | | | |
|---|---|---|---|---|---|---|
| | 612 | | ការជួលមធ្យោបាយដឹកញ្ជូន | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 613 | | ថ្លៃឈ្នួលនិងបន្ទុក(អសង្ហារឹម) | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 614 | | សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 615 | | ការថែទាំនិងជួសជុល | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6151 | ការថែទាំដីធ្លី សួនច្បារ និងរៀបជាជួរ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6152 | ការថែទាំទីផ្សារ សត្តឃាតដ្ឋាន និងអគារសាធារណៈ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6153 | ការថែទាំ ជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងប្រព័ន្ធលូ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6154 | ការថែទាំបណ្តាញផ្សេងៗ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6155 | ការថែទាំនិងជួសជុលឧបករណ៍ សម្ភារៈការិយាល័យ សម្ភារៈព័ត៌មានវិទ្យា និងទូរគមនាគមន៍ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6156 | ការថែទាំនិងជួសជុលមធ្យោបាយដឹកជញ្ជូន | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6157 | ការថែទាំនិងជួសជុលសម្ភារៈឧបករណ៍បច្ចេកទេស | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 616 | | សោហ៊ុយធានារ៉ាប់រង | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 617 | | សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និង សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6171 | សោហ៊ុយសិក្សាពិសោធន៍ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6172 | សោហ៊ុយនៃការប្រើប្រាស់សេវា | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6173 | សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6174 | សំណងផ្នែកស៊ីវិល | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 618 | | សោហ៊ុយដឹកជញ្ជូន | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6181 | សម្ភារៈ និងទំនិញ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| **62** | សេវាខាងក្រៅផ្សេងៗ | | | | | |
| | 621 | | បុគ្គលិកខាងក្រៅ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6211 | ភ្នាក់ងារជាតិជាប់កិច្ចសន្យា | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6212 | ភ្នាក់ងារបរទេសជាប់កិច្ចសន្យា | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6213 | បុគ្គលិកសមូហភាពសាធារណៈផ្សេងៗ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 622 | | ទំនាក់ទំនងសាធារណៈនិងការផ្សព្វផ្សាយ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6221 | សោហ៊ុយទទួលភ្ញៀវជាតិ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6222 | សោហ៊ុយទទួលភ្ញៀវបរទេស | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6223 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6224 | សោហ៊ុយពិធីបុណ្យ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6225 | ការទិញវត្ថុអនុស្សាវរីយ៍ក្នុងនិងក្រៅប្រទេស | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6226 | សោហ៊ុយសម្រាប់ការតាំងពិព័រណ៍នៅក្នុងនិងក្រៅប្រទេស | ឥណពន្ធ | ឥណទាន | ឥណាយិក |

| | | | | | | |
|---|---|---|---|---|---|---|
| | | 6227 | ការឃោសនានិងផ្សព្វផ្សាយព័ត៌មានសាធារណៈ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 623 | | សោហ៊ុយដាវសារព័ត៌មាននិងឯកសារ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 624 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6241 | សោហ៊ុយដឹកជញ្ជូន | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6242 | សោហ៊ុយបេសកកម្ម | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6243 | សោហ៊ុយស្នាក់នៅ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 625 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6251 | សោហ៊ុយដឹកជញ្ជូន | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6252 | សោហ៊ុយបេសកកម្ម | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6253 | សោហ៊ុយស្នាក់នៅ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 626 | | សោហ៊ុយទូរគមនាគមន៍ ទូរស័ព្ទតេឡិច និងទូរសារប្រៃសណីយ៍ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6261 | សោហ៊ុយប្រៃសណីយ៍ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6262 | សោហ៊ុយទូរគមនាគមន៍ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 627 | | សោហ៊ុយធនាគារ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 628 | | សោហ៊ុយផ្សេងៗ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| **63** | ពន្ធនិងអាករ | | | | | |
| | 631 | | លតាបត្រ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 633 | | បន្ទុកពន្ធប្រថាប់ត្រា | ឥណពន្ធ | ឥណទាន | ឥណាយិក |
| **64** | បន្ទុកបុគ្គលិក | | | | | |
| | 641 | | លាភការនិងប្រាក់បំណាច់នៃអំណាចសាធារណៈ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6411 | ប្រាក់បំណាច់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6412 | ប្រាក់បំណាច់អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6413 | លាភការទីប្រឹក្សា | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6414 | លាភការបេសកជន | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 642 | | លាភការនិងប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6421 | បៀវត្សមូលដ្ឋាន | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6422 | ប្រាក់បំណាច់មុខងារ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6423 | ប្រាក់បំណាច់ម៉ោងបន្ថែម | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6424 | ប្រាក់បំណាច់តំបន់ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6425 | ប្រាក់បំណាច់ទទួលខុសត្រូវ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6426 | ប្រាក់បំណាច់ការងារធ្ងន់និងប៉ះពាល់សុខភាព | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 643 | | រង្វាន់និងប្រាក់បំណាច់ផ្សេងៗទៀត | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6431 | កន្សោមអាទិភាព | ឥណពន្ធ | ឥណទាន | ឥណាយិក |

| | | | | | | |
|---|---|---|---|---|---|---|
| | | 6432 | ប្រាក់បំណាច់សម្រាប់ប្រឡង-ប្រឡងប្រជែង | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6433 | វង្វាន់ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6434 | ប្រាក់បំណាច់បុគ្គលិកក្រសួងផ្សេងៗ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6438 | ផ្សេងៗ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 644 | | លាភការនិងប្រាក់បំណាច់បុគ្គលិកមិនមែនក្របខណ្ឌនិងបុគ្គលិកអណ្តែត | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6441 | បៀវត្សមូលដ្ឋានបុគ្គលិកមិនមែនក្របខណ្ឌ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6442 | លាភការផ្សេងៗទៀតបុគ្គលិកមិនមែនក្របខណ្ឌ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6443 | បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6444 | លាភការផ្សេងៗទៀតបុគ្គលិកអណ្តែត | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6445 | ប្រាក់ឧបត្ថម្ភភូមិ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 645 | | ប្រាក់វិភាជន៍សង្គម | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6451 | ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6452 | មន្ត្រីមានជំងឺនិងឧបត្ថម្ភអ្នកសម្រាលកូន | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6453 | មរណៈភាព | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6454 | ឧបត្ថម្ភនិវត្តជន | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6455 | ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6456 | គ្រោះថ្នាក់ការងារនិងទុព្វលភាព | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6457 | ឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីរាជការ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6458 | ផ្សេងៗ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| **65** | **ឧបត្ថម្ភធននិងជំនួយសង្គម** | | | | | |
| | 651 | | ឧបត្ថម្ភធនដល់រដ្ឋបាលដែនដី | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6511 | ឧបត្ថម្ភធនដល់ក្រុង ស្រុក ខណ្ឌ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6512 | ឧបត្ថម្ភធនដល់ឃុំ សង្កាត់ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6513 | ឧបត្ថម្ភគ្រឹះស្ថានសាធារណៈរដ្ឋបាល | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 652 | | ជំនួយសង្គមនិងប្រាក់វិភាជន៍ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6521 | ជំនួយដល់ប្រជាជនក្រីក្រសម្រាកពេទ្យ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6522 | ជួយជនរងគ្រោះដោយធម្មជាតិ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6528 | ចំណាយសង្គមផ្សេងៗទៀត | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 653 | | ឧបត្ថម្ភធនដល់អង្គភាពមានលក្ខណៈសង្គមនិងវប្បធម៌ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6531 | ឧបត្ថម្ភមណ្ឌលកុមារកំព្រា | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6532 | ឧបត្ថម្ភសហគមន៍កីឡានិងវប្បធម៌ | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6533 | ឧបត្ថម្ភកាកបាទក្រហម | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6534 | ឧបត្ថម្ភដល់អង្គការមូលដ្ឋាននិងគាំទ្រកម្មវិធីផ្សេងៗ | ឥណពន្ធ | ឥណទាន | ឥណាយិក |

| | | | | | | |
|---|---|---|---|---|---|---|
| | 654 | | ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 656 | | វិភាគទានដល់អង្គការអន្តរជាតិនានា | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | | 6568 | អង្គការអន្តរជាតិផ្សេងៗទៀត | ឥណពន្ធ | ឥណទាន | ឥណាយិក |
| 66 | បន្ទុកហិរញ្ញវត្ថុ | | | ឥណពន្ធ | ឥណទាន | ឥណាយិក |
| 67 | បន្ទុកពិសេស | | | | | |
| | 671 | | ឥណទេយ្យដែលទទួលស្គាល់តែទារមិនបាន | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 675 | | តំលៃគណនេយ្យនៃចំណែកសកម្មបានលក់ (តំលៃនៅសល់) | ឥណពន្ធ | ឥណទាន | ឥណាយិក |
| 68 | ទាយជ្ជទានអោយដល់រំលស់អចលកម្ម | | | | | |
| | 681 | | ទាយជ្ជទានអោយដល់រលស់អចលកម្មអរូបី | ឥណពន្ធ | ឥណទាន | ឥណាយិក |
| | 682 | | ទាយជ្ជទានអោយដល់រំលស់អចលកម្មរូបី | ឥណពន្ធ | ឥណទាន | ឥណាយិក |
| ថ្នាក់ ៧ : គណនី ចំណូល | | | | | | |
| 70 | ចំណូលសារពើពន្ធ | | | | | |
| | 701 | | ពន្ធលើបេតិកភ័ណ្ឌ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7011 | ពន្ធប្រថាប់ត្រា-ពន្ធផ្ទេរមរតកវាំងអ្នកនៅរស់ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7012 | ពន្ធប្រថាប់ត្រា-ពន្ធផ្ទេរសិទ្ធិពីអ្នកស្លាប់ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7013 | ពន្ធលើដីធ្លីមិនបានប្រើប្រាស់ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 702 | | ពន្ធលើទ្រព្យសម្បត្តិដែលបានកំណត់ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7021 | អាករសម្រាប់បំភ្លឺសាធារណៈ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 703 | | ពន្ធលើសេវាដែលបានកំណត់ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7031 | អាករលើការស្នាក់នៅ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7032 | ពន្ធសត្តឃាត | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 704 | | អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិឬការអនុវត្តសកម្មភាព | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7041 | ពន្ធប៉ាតង់ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7042 | ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានយន្តគ្រប់ប្រភេទ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 707 | | ពន្ធលើអចលនទ្រព្យ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7071 | ពន្ធលើអចលនទ្រព្យរូបវន្តបុគ្គល | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7072 | ពន្ធលើអចលនទ្រព្យនីតិបុគ្គល | ឥណទាន | ឥណពន្ធ | ឥណទាយី |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | | | | | |
| | 721 | | ផលនៃការជួលដីធ្លី | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7211 | សម្បទានពីរ៉ែ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7212 | ការជួលកន្លែងលក់ដូរក្នុងទីផ្សារ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7213 | ចំណូលពីចំណតរថយន្ត | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7214 | ចំណូលពីចំណតជលយាន | ឥណទាន | ឥណពន្ធ | ឥណទាយី |

| | | | | | | |
|---|---|---|---|---|---|---|
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | | | | | |
| | 731 | | សហគ្រាសសាធារណៈ-រដ្ឋបាល និងសេវាទ្រព្យសម្បត្តិ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 732 | | ផលពីការគ្រប់គ្រងរដ្ឋបាល | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7321 | សេវាសុរិយោដី | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7322 | សេវាសំណង់ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7323 | ចំណូលសម្រាប់ទម្រង់ការរដ្ឋបាល | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7324 | ចំណូលពីការអនុញ្ញាតរដ្ឋបាល | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7325 | សេវាត្រួតពិនិត្យអនាម័យសត្វនៅសត្តឃាតដ្ឋាន | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7328 | ចំណូលរដ្ឋបាលផ្សេងៗទៀត | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 733 | | ការជួលទ្រព្យសម្បត្តិអចល័ត | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7331 | ចំណូលពីសត្តឃាតដ្ឋាន | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7332 | ការជួលកន្លែងលក់ដូរក្នុងទីផ្សារ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7333 | ចំណូលពីកំពង់ចម្លង | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7334 | ចំណូលពីឃ្លាំងត្រីនិងពីកន្លែងបែងចែកផលិតផល | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7335 | ចំណូលពីភាស៊ីផ្សារ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7338 | ការជួលទ្រព្យសម្បត្តិអចល័តផ្សេងៗទៀត | ឥណទាន | ឥណពន្ធ | ឥណទាយី |
| 74 | ផលពីការពិន័យនិងការដាក់ទណ្ឌកម្ម | | | | | |
| | 741 | | ផលពីការពិន័យនិងការដាក់ទណ្ឌកម្ម | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 742 | | ផលពីការទប់ស្កាត់និងបង្ក្រាបអំពើគេចពន្ធគយ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| 75 | ការឧបត្ថម្ភកធន | | | | | |
| | 751 | | ទាយជ្ជទានសម្រាប់ដំណើរការដែលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 752 | | ទាយជ្ជទានសម្រាប់ដំណើរការដែលឧបត្ថម្ភពីថវិការាជធានី ខេត្ត | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 753 | | ទាយជ្ជទានសម្រាប់ដំណើរការដែលឧបត្ថម្ភពីថវិកាក្រុង ស្រុក ខណ្ឌ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 754 | | ការចូលរួមធនធានពីសមាសភាគអភិវឌ្ឍមូលដ្ឋាន | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 755 | | ការចូលរួមធនធានពីដៃគូអភិវឌ្ឍ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 756 | | ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7561 | ពីក្រសួង ស្ថាប័ន | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7562 | ពីមន្ទីរជំនាញ | ឥណទាន | ឥណពន្ធ | ឥណទាកើ |
| | | 7563 | ពីរាជធានី ខេត្ត | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | | 7564 | ពីក្រុង ស្រុក ខណ្ឌ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 758 | | ចំណូលឧបត្ថម្ភពីប្រភពផ្សេងៗ | ឥណទាន | ឥណពន្ធ | ឥណទាយី |
| 76 | ផលហិរញ្ញវត្ថុ | | | | | |
| | 768 | | ផលហិរញ្ញវត្ថុផ្សេងទៀត | ឥណទាន | ឥណពន្ធ | ឥណទាយី |

| | | | | | | |
|---|---|---|---|---|---|---|
| 77 | ផលផ្សេងៗនិងផលពិសេស | | | | | |
| | 775 | | ផលពីការលក់អចលកម្ម | ឥណទាន | ឥណពន្ធ | ឥណទាយី |
| | 777 | | ចំណែកនៃឧបត្ថម្ភកធននិវិយោគផ្ទេរចូលគណនីលទ្ធផល | ឥណទាន | ឥណពន្ធ | ឥណទាយី |
| 78 | ការងារនៃរជ្ជទេយ្យ | | | ឥណទាន | ឥណពន្ធ | ឥណទាយី |

## <u>ឧបសម្ព័ន្ធ ២</u>: ប្រព្រឹត្តិកម្មគណនី នៃប្លង់គណនេយ្យរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

### ១- គណនី ទាយជធាន " លេខ ១០១ " :

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាតម្លៃអចលកម្មអរូបី អចលកម្មរូបី ដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានកន្លងមក និងកត់ត្រាតម្លៃនៃទ្រព្យអកម្មដែលបានធ្វើសមាហរណ៍កម្ម។ តម្លៃនៃទ្រព្យសម្បត្តិ និង តម្លៃនៃបំណុលអកម្មទាំងនេះ បានមកពីការវាយតម្លៃនៅលើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិ និងរបាយការណ៍ស្តីពីបំណុលអកម្ម។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ទ្រព្យអកម្មដែលបានធ្វើសមាហរណ៍កម្ម

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់នៃតម្លៃអចលកម្មរូបី អរូបីដែលបានចាត់ទុកជាធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ដែលជាធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នៃតម្លៃអចលកម្ម និងតម្លៃ នៃទ្រព្យអកម្មផ្សេងៗទៀត ។

<u>ចំណាំ</u> : តម្លៃអចលកម្ម ដែលកើតមានក្រោយពីការធ្វើសមាហរណ៍កម្ម គឺត្រូវកត់ត្រាតាមចំនួនទឹកប្រាក់ដែលបានទូទាត់ពេលទិញ ឬសាងសង់ទៅក្នុងគណនីអចលកម្ម ដោយមិនប្រើគណនីនេះទេ។

### ២-គណនី ធនធានអចលកម្មដែលបានទទួលគ្រប់គ្រង ប្រើប្រាស់ " លេខ ១០២ " :

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រានូវចំនួនទឹកប្រាក់នៃប្រភពធនធានអចលកម្មដែលរដ្ឋបាលថ្នាក់ក្រោមជាតិ បានទទួលមកធ្វើការគ្រប់គ្រងបន្ត។ ភាគីជាអ្នកទទួលនឹងក្លាយទៅជាកម្មសិទ្ធិករ។

ការកត់ត្រា:

ឥណពន្ធ : - កត់ត្រាតម្លៃអចលកម្ម ដែលបានផ្ទេរការគ្រប់គ្រងវិញ
- កត់ត្រាតម្លៃអចលកម្ម ដែលបានផ្ទេរទៅ

ឥណទាន : - កត់ត្រាតម្លៃអចលកម្ម ដែលបានទទួលមកគ្រប់គ្រង
- កត់ត្រាចំនួនទឹកប្រាក់រំលស់នៃអចលកម្ម ដែលបានផ្ទេរមក

សមតុល្យ : ឥណទាយី បង្ហាញប្រភពធនធាននៃតម្លៃអចលកម្ម ដែលបានទទួលមកធ្វើការគ្រប់គ្រង។

### ៣-គណនី ធនធានបានពីអំណោយ និងកេរ្តិ៍មរតក " លេខ ១០៤ " :

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាតម្លៃនៃទ្រព្យសម្បត្តិ ដែលបានមកពីអំណោយ ឬ មរតកអ្នកដែលបានទទួលមរណៈភាព ផ្តល់ជូនជាកម្មសិទ្ធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ការកត់ត្រា:

ឥណពន្ធ : ពុំមានប្រតិបត្តិការ

ឥណទាន : កត់ត្រាតម្លៃទ្រព្យសម្បត្តិ ដែលបានទទួល

សមតុល្យ : ឥណទាយី បង្ហាញតម្លៃអចលកម្មបានពីអំណោយ និងកេរ្តិ៍មរតកដែលបានទទួល និងចាត់ទុកជាធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**៤-គណនី ចំណែកនៃអតិរេកចរន្តបានប្រើសម្រាប់ចំណាយវិនិយោគ "លេខ ១០៦":**

គណនីនេះបើកនៅតេនាគាររាជធានី ខេត្តប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់អតិរេកថវិកាផ្នែកចរន្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានប្រើប្រាស់លើចំណាយវិនិយោគ។

ការកត់ត្រា:

ឥណពន្ធ : ពុំមានប្រតិបត្តិការ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់អតិរេកដែលបានផ្ទេរមកពីគណនីលទ្ធផលនៃការិយបរិច្ឆេទ ឬ ពីគណនីយោងជាថ្មី (ឥណទាយី) ដែលស្មើនឹងចំនួនទឹកប្រាក់ឱនភាពថវិកាផ្នែកវិនិយោគ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់នៃអតិរេកផ្នែកចរន្តដែលបានប្រើប្រាស់លើចំណាយវិនិយោគបូកបន្ត។

**៥-គណនី យោងជាថ្មី ឥណទាយី (អតិរេក) "លេខ ១១០":**

គណនីនេះបើកនៅតេនាគាររាជធានី ខេត្ត ប្រើ សម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្ទេរពីគណនីលទ្ធផលនៃការិយបរិច្ឆេទមក។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់នៃលទ្ធផល ឱនភាពដែលបានផ្ទេរមក

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់នៃលទ្ធផល អតិរេកដែលបានផ្ទេរមក

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់នៃលទ្ធផលអតិរេកបូកបន្ត។

<u>ចំណាំ</u> : ការជម្រះផ្ទេរលទ្ធផលនៃការិយបរិច្ឆេទមកគណនីយោងជាថ្មី គឺនៅក្នុងឆ្នាំបន្ទាប់។

**៦-គណនី យោងជាថ្មី ឥណាយិក (ឱនភាព) "លេខ ១១៩":**

គណនីនេះបើកនៅតេនាគាររាជធានី ខេត្ត ប្រើ សម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្ទេរពីគណនីលទ្ធផលនៃការិយបរិច្ឆេទមក។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់នៃលទ្ធផល ឱនភាពដែលបានផ្ទេរមក

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់នៃលទ្ធផល អតិរេកដែលបានផ្ទេរមក

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់នៃ លទ្ធផលឱនភាពបូកបន្ត។

<u>ចំណាំ</u> : ការជម្រះផ្ទេរលទ្ធផលពីគណនីលទ្ធផលនៃការិយបរិច្ឆេទមកគណនីយោងជាថ្មី គឺនៅក្នុងឆ្នាំបន្ទាប់។

**៧-គណនី លទ្ធផលនៃការិយបរិច្ឆេទ "លេខ ១២១":**

គណនីនេះបើកនៅតេនាគាររាជធានី ខេត្តប្រើសម្រាប់កត់ត្រាការគណនារកលទ្ធផលនៃការអនុវត្តថវិកាចរន្តក្នុងការិយបរិច្ឆេទ ដោយផ្ទេរសមតុល្យពិតចុងឆ្នាំពីគណនីចំណូលនិងគណនីចំណាយចរន្តមក។

ការកត់ត្រា:

ឥណពន្ធ : - កត់ត្រាផ្ទេរសមតុល្យឥណាយិកពីគណនី ចំណាយថវិកាចរន្ត
- កត់ត្រាផ្ទេរលទ្ធផលអតិរេកចូលគណនី យោងជាថ្មី ឥណទាយី ឬគណនី យោងជាថ្មី ឥណាយិក
- កត់ត្រាផ្ទេរលទ្ធផលអតិរេកចូលគណនី ចំណែកនៃអតិរេកចរន្តបានប្រើសម្រាប់ចំណាយវិនិយោគ

ឥណទាន : - កត់ត្រាផ្ទេរសមតុល្យឥណទាយីពីគណនី ចំណូលថវិកាចរន្ត

- កត់ត្រាផ្ទេរលទ្ធផលឱនភាពចូលគណនី យោងជាថ្មី ឥណពន្ធ ឬគណនី យោងជាថ្មី ឥណទាន

សមតុល្យ : - ឥណទាយី បង្ហាញលទ្ធផល អតិរេក នៃការអនុវត្តថវិកាចរន្ត ដែលពុំទាន់បានចាត់ចែង
- ឥណពន្ធ បង្ហាញលទ្ធផល ឱនភាព នៃការអនុវត្តថវិកាចរន្ត ដែលពុំទាន់បានចាត់ចែង។

ចំណាំ : គណនីនេះត្រូវអេសមតុល្យនៅក្រោយពេលចាត់ចែងលទ្ធផលប្រចាំឆ្នាំរួច នៅឆ្នាំបន្ទាប់។

**៨-គណនី ឧបត្ថម្ភធន ទព្វសម្ភារៈ បរិក្ខារ ទ្រព្យគី "លេខ ១៣១" :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានមកពីការផ្តល់ឧបត្ថម្ភធនជាទព្វសម្ភារៈ ឬជាសាច់ប្រាក់សម្រាប់ទិញ សាងសង់ទ្រព្យសម្ភារៈ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានជម្រះនូវឧបត្ថម្ភធនជាទព្វសម្ភារៈបានទទួលជាមួយនឹងចំណែកនៃឧបត្ថម្ភធនវិនិយោគដែលបានផ្ទេរចូលគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាតម្លៃទព្វសម្ភារៈ ឬប្រាក់ដែលបានមកពីការផ្តល់ដោយប្រភពនានា

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់នៃឧបត្ថម្ភធនវិនិយោគដែលបានទទួល និងដែលពុំទាន់ជម្រះ។

ចំណាំ : - ការជម្រះផ្នែកខាងឥណពន្ធនៃគណនីលេខ ១៣១ នៅពេលដែលចំនួនទឹកប្រាក់សរុបខាងផ្នែកឥណទាននៃគណនីនេះស្មើនឹងទឹកប្រាក់សរុបខាងផ្នែកឥណពន្ធនៃគណនីលេខ១៣៩ នៃប្រភេទឧបត្ថម្ភធននីមួយៗ។
- ការជម្រះគណនីលេខ ១៣១ និងគណនីលេខ ១៣៩ គឺជាប្រតិបត្តិការតាមដីកា។

**៩-គណនី ទាយជ្ជទានសម្រាប់វិនិយោគដែលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ "លេខ ១៣២" :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានមកពីការផ្តល់ឧបត្ថម្ភធនពីថវិកាថ្នាក់ជាតិសម្រាប់វិនិយោគ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានជម្រះនូវឧបត្ថម្ភពីថវិកាថ្នាក់ជាតិបានទទួលជាមួយនឹងចំណែកនៃឧបត្ថម្ភធនវិនិយោគដែលបានផ្ទេរចូលគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ឧបត្ថម្ភដែលបានឧបត្ថម្ភពីថវិកាថ្នាក់ជាតិ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ឧបត្ថម្ភសម្រាប់វិនិយោគដែលបានទទួលពីថវិកាថ្នាក់ជាតិ និងដែលពុំទាន់ជម្រះ។

ចំណាំ : - ការជម្រះផ្នែកខាងឥណពន្ធនៃគណនីលេខ ១៣២ នៅពេលដែលចំនួនទឹកប្រាក់សរុបខាងផ្នែកឥណទាននៃគណនីនេះស្មើនឹងទឹកប្រាក់សរុបខាងផ្នែកឥណពន្ធនៃគណនីលេខ១៣៩ នៃប្រភេទឧបត្ថម្ភធននីមួយៗ។
- ការជម្រះ គណនីលេខ ១៣២ និងគណនីលេខ ១៣៩ គឺជាប្រតិបត្តិការតាមដីកា។

**១០-គណនី ទាយជ្ជទានសម្រាប់វិនិយោគដែលឧបត្ថម្ភពីថវិការាជធានី ខេត្ត "លេខ១៣៣":**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានមកពីការផ្តល់ឧបត្ថម្ភធនពីថវិការាជធានី ខេត្តសម្រាប់វិនិយោគ។

ការកត់ត្រាៈ

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានជម្រះនូវឧបត្ថម្ភពីថវិការាជធានី ខេត្តបានទទួលជាមួយនឹងចំណែកនៃឧបត្ថម្ភកធនវិនិយោគដែលបានផ្ទេរចូលគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានឧបត្ថម្ភពីថវិការាជធានី ខេត្ត

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ឧបត្ថម្ភសម្រាប់វិនិយោគដែលបានទទួលពីថវិការាជធានី ខេត្ត និងដែលពុំទាន់ជម្រះ។

ចំណាំ : - ការជម្រះផ្នែកខាងឥណពន្ធនៃគណនីលេខ ១៣៣ នៅពេលដែលចំនួនទឹកប្រាក់សរុបខាងផ្នែកឥណទាននៃគណនីនេះស្មើនឹងទឹកប្រាក់សរុបខាងផ្នែកឥណពន្ធនៃគណនីលេខ១៣៩ នៃប្រភេទឧបត្ថម្ភកធននីមួយៗ។

- ការជម្រះ គណនីលេខ ១៣៣ និងគណនីលេខ ១៣៩ គឺជាប្រតិបត្តិការតាមដីកា។

**១១-គណនី ទាយជ្ញទានសម្រាប់វិនិយោគដែលឧបត្ថម្ភពីថវិកាក្រុង ស្រុក ខណ្ឌ "លេខ ១៣៤":**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានមកពីការផ្តល់ឧបត្ថម្ភកធនពីថវិកាក្រុង ស្រុក ខណ្ឌសម្រាប់វិនិយោគ។

ការកត់ត្រាៈ

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានជម្រះនូវឧបត្ថម្ភពីថវិកាក្រុង ស្រុក ខណ្ឌ បានទទួលជាមួយនឹងចំណែកនៃឧបត្ថម្ភកធនវិនិយោគដែលបានផ្ទេរចូលគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានឧបត្ថម្ភពីថវិកាក្រុង ស្រុក ខណ្ឌ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ឧបត្ថម្ភសម្រាប់វិនិយោគដែលបានទទួលពីថវិកាក្រុង ស្រុក ខណ្ឌ និងដែលពុំទាន់ជម្រះ។

ចំណាំ : - ការជម្រះផ្នែកខាងឥណពន្ធនៃគណនីលេខ ១៣៤ នៅពេលដែលចំនួនទឹកប្រាក់សរុបខាងផ្នែកឥណទាននៃគណនីនេះស្មើនឹងទឹកប្រាក់សរុបខាងផ្នែកឥណពន្ធនៃគណនីលេខ១៣៩ នៃប្រភេទឧបត្ថម្ភកធននីមួយៗ។

- ការជម្រះ គណនីលេខ ១៣៤ និងគណនីលេខ ១៣៩ គឺជាប្រតិបត្តិការតាមដីកា។

**១២-គណនី ចំណូលពីការរួមចំណែករបស់ប្រជាជនក្នុងការអនុវត្តគម្រោង "លេខ ១៣៥":**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានមកពីការចូលរួមចំណែករបស់ប្រជាជនក្នុងការអនុវត្តគម្រោងសម្រាប់ការអភិវឌ្ឍមូលដ្ឋាន។

ការកត់ត្រាៈ

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានជម្រះនូវធនធានរួមចំណែករបស់ប្រជាជន ជាមួយនឹងចំណែកនៃឧបត្ថម្ភកធនវិនិយោគដែលបានផ្ទេរចូលគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានទទួលពីការរួមចំណែករបស់ប្រជាជនទៅក្នុងការអនុវត្តគម្រោង

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ដែលបានទទួលពីការរួមចំណែករបស់ប្រជាជនទៅក្នុងគម្រោង និងដែលពុំទាន់ជម្រះ។

<u>ចំណាំ</u> : - ការជម្រះផ្នែកខាងឥណពន្ធនៃគណនីលេខ ១៣៥ នៅពេលដែលចំនួនទឹកប្រាក់សរុបខាងផ្នែកឥណទាននៃគណនីនេះស្មើនឹងទឹកប្រាក់សរុបខាងផ្នែកឥណពន្ធនៃគណនីលេខ១៣៩ នៃប្រភេទឧបត្ថម្ភកធននីមួយៗ។

- ការជម្រះ គណនីលេខ ១៣៥ និងគណនីលេខ ១៣៩ គឺជាប្រតិបត្តិការតាមដីកា។

**១៣-គណនី ការចូលរួមធនធានពីដៃគូអភិវឌ្ឍ "លេខ ១៣៦" :**

គណនីនេះបើកនៅតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានមកពីការចូលរួមធនធានរបស់ដៃគូអភិវឌ្ឍសម្រាប់ការអភិវឌ្ឍមូលដ្ឋាន។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានជម្រះនូវធនធានពីដៃគូអភិវឌ្ឍដែលបានទទួល ជាមួយនឹងចំណែកនៃឧបត្ថម្ភកធនវិនិយោគដែលបានផ្ទេរចូលគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានចូលរួមពីដៃគូអភិវឌ្ឍ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ដែលបានចូលរួមជាធនធានពីដៃគូអភិវឌ្ឍនិងដែលពុំទាន់ជម្រះ។

<u>ចំណាំ</u> : - ការជម្រះផ្នែកខាងឥណពន្ធនៃគណនីលេខ ១៣៦ នៅពេលដែលចំនួនទឹកប្រាក់សរុបខាងផ្នែកឥណទាននៃគណនីនេះស្មើនឹងទឹកប្រាក់សរុបខាងផ្នែកឥណពន្ធនៃគណនីលេខ១៣៩ នៃប្រភេទឧបត្ថម្ភកធននីមួយៗ។

- ការជម្រះគណនីលេខ ១៣៦ និងគណនីលេខ ១៣៩ គឺជាប្រតិបត្តិការតាមដីកា។

**១៤-គណនី ចំណូលមូលធនពីប្រភពផ្សេងៗ "លេខ ១៣៨" :**

គណនីនេះបើកនៅតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានមកពីមូលធនពីប្រភពផ្សេងៗ សម្រាប់ការអភិវឌ្ឍមូលដ្ឋាន។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានជម្រះនូវឧបត្ថម្ភមូលធនពីប្រភពផ្សេងៗ ជាមួយនឹងចំណែកនៃឧបត្ថម្ភកធនវិនិយោគដែលបានផ្ទេរចូលគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានពីមូលធនពីប្រភពផ្សេងៗ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ដែលបានពីមូលធនពីប្រភពផ្សេងៗ និងដែលពុំទាន់ជម្រះ។

<u>ចំណាំ</u> : - ការជម្រះផ្នែកខាងឥណពន្ធនៃគណនីលេខ ១៣៨ នៅពេលដែលចំនួនទឹកប្រាក់សរុបខាងផ្នែកឥណទាននៃគណនីនេះស្មើនឹងទឹកប្រាក់សរុបខាងផ្នែកឥណពន្ធនៃគណនីលេខ១៣៩ នៃប្រភេទឧបត្ថម្ភកធននីមួយៗ។

- ការជម្រះគណនីលេខ ១៣៨ និងគណនីលេខ ១៣៩ គឺជាប្រតិបត្តិការតាមដីកា។

**១៥-គណនី ឧបត្ថម្ភកធនវិនិយោគផ្ទេរទៅគណនីលទ្ធផល "លេខ ១៣៩" :**

គណនីនេះបើកនៅតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ នៃចំណែកឧបត្ថម្ភកធនវិនិយោគដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទនីមួយៗ។

ការកត់ត្រា:

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់នៃចំណែកឧបត្ថម្ភកធនវិនិយោគ ដែលបានផ្ទេរទៅគណនីលទ្ធផល

តាមរយៈ គណនី ចំណូលថវិកា (ស្មើនឹងចំនួនទឹកប្រាក់រំលស់អចលកម្ម)

- កត់ត្រាចំនួនទឹកប្រាក់នៃចំណែកឧបត្ថម្ភកធនវិនិយោគ ដែលបានកត់ត្រាបន្ថែមចូលគណនីលទ្ធផលចរន្ត តាមរយៈគណនីចំណូលថវិកា។

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់នៃចំណែកឧបត្ថម្ភកធនវិនិយោគ ដែលបានបូកបន្តហើយបាន ជម្រះជាមួយគណនី ឧបត្ថម្ភកធនវិនិយោគដែលបានទទួល

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់បូកបន្តនៃចំណែកឧបត្ថម្ភកធនវិនិយោគដែលពុំទាន់បានជម្រះជាមួយគណនី ឧបត្ថម្ភកធនវិនិយោគ។

**១៦-គណនី ប្រាក់តម្កល់ធានាសកម្មភាពអាជីវកម្មបានទទួល "លេខ ១៦៤":**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានទទួលពីការតម្កល់ធានាលើសកម្មភាពអាជីវកម្មរបស់អាជីវករ ក្រុមហ៊ុន ដោយបង់ជាសាច់ប្រាក់ ជាមូលប្បទានបត្រ ឬបង្វែរចូលគណនីចរន្តរបស់រតនាគារ។

ការកត់ត្រា:

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់តម្កល់ធានាដែលបានសងទៅអាជីវករ ឬក្រុមហ៊ុនវិញ

- កត់ត្រាចំនួនទឹកប្រាក់តម្កល់ធានាដែលបានផ្ទេរទៅជាចំណូលថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់តម្កល់ធានាដែលបានទទួលពីអាជីវករ ឬក្រុមហ៊ុន

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់តម្កល់ធានាសកម្មភាពអាជីវកម្មដែលពុំទាន់បានសងទៅអាជីវករ ឬក្រុមហ៊ុនវិញ។

**១៧-គណនី ការបែងចែកទ្រព្យសម្បត្តិ "លេខ ១៨១":**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាតម្លៃអចលកម្មដែលបានផ្ទេររវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីប្រើប្រាស់ តែនៅជាកម្មសិទ្ធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលជាអ្នកផ្ទេរ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ស្មើនឹងតម្លៃអចលកម្មដែលបានផ្ទេរ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ស្មើនឹងតម្លៃអចលកម្មដែលបានទទួល

សមតុល្យ : - ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់សរុបស្មើនឹងតម្លៃអចលកម្មដែលបានផ្ទេរ

- ឥណទាយី បង្ហាញចំនួនទឹកប្រាក់សរុបស្មើនឹងតម្លៃអចលកម្មដែលបានទទួល។

**១៨-គណនី សោហ៊ុយសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍន៍ "លេខ ២០៣":**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានចំណាយលើការសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍន៍។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍន៍

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយលើការសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍន៍ ដែលបានជម្រះជាមួយនឹងទឹកប្រាក់រំលស់បូកបន្ត

សមតុល្យ : ឥណពន្ធ បង្ហាញតម្លៃនៃការសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍន៍កំពុងធ្វើ។

**១៩-គណនី ប្រកាសនីយបត្រ អាជ្ញាប័ណ្ណ និងសិទ្ធិប្រហាក់ប្រហែល "លេខ ២០៥" :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយដើម្បីបង្កើត ឬទិញប្រកាសនីយបត្រ អាជ្ញាប័ណ្ណ ម៉ាកសម្គាល់ សិទ្ធិប្រហាក់ប្រហែល និងកម្មវិធីកុំព្យូទ័រ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានទិញបង្កើតប្រកាសនីយបត្រ អាជ្ញាប័ណ្ណ ម៉ាកសម្គាល់ សិទ្ធិប្រហាក់ប្រហែល និងកម្មវិធីកុំព្យូទ័រ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់នៃប្រកាសនីយបត្រ អាជ្ញាប័ណ្ណ ម៉ាកសម្គាល់ សិទ្ធិប្រហាក់ប្រហែល និងកម្មវិធីកុំព្យូទ័រ ដែលបានបន្ថយដោយលក់ ធ្វើអំណោយ ផ្ទេរ ឬជម្រះ

សមតុល្យ : ឥណពន្ធ បង្ហាញតម្លៃប្រកាសនីយបត្រ អាជ្ញាប័ណ្ណ ម៉ាកសម្គាល់ សិទ្ធិប្រហាក់ប្រហែល និងកម្មវិធីកុំព្យូទ័រ ដែលកំពុងមាន។

**២០-គណនី ដីធ្លី និងធនធានធម្មជាតិ "លេខ ២១១" :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាតម្លៃដីធ្លី និងធនធានធម្មជាតិដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានពីអំណោយ ទិញ និងបានពីរូបភាពផ្សេងទៀត។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាតម្លៃដីធ្លីនិងធនធានធម្មជាតិដែលបានបញ្ចូលជាទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ឥណទាន : កត់ត្រាតម្លៃដីធ្លី និងធនធានធម្មជាតិដែលបានបន្ថយដោយលក់ ធ្វើអំណោយ ឬផ្ទេរ

សមតុល្យ : ឥណពន្ធ បង្ហាញតម្លៃដីធ្លីនិងធនធានធម្មជាតិ ដែលកំពុងគ្រប់គ្រង។

<u>ចំណាំ</u> : តម្លៃដីធ្លីពុំមានការគិតរំលស់ឡើយ។

**២១-គណនី ការរៀបចំ កែលំអដីធ្លី "លេខ ២១២" :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានចំណាយលើការកែលំអដីធ្លី។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការកែលំអដីធ្លី

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានជម្រះជាមួយនឹងទឹកប្រាក់រំលស់បូកបន្តនិងគណនីតម្លៃគណនេយ្យនៃចំណែកសកម្មដែលបានលក់ ឬជម្រះ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ដែលបានចំណាយលើការកែលំអដីធ្លីពុំទាន់បានជម្រះ។

**២២-គណនី សំណង់ "លេខ ២១៣" :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាតម្លៃសំណង់ អាគារដែលបានទិញ សាងសង់ ឬ បានពីអំណោយ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាតម្លៃសំណង់ អាគារដែលបានបញ្ចូលជាទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ឥណទាន : កត់ត្រាតម្លៃសំណង់ អាគារដែលបានបន្ថយដោយលក់ ធ្វើអំណោយ ផ្ទេរ ឬជម្រះ

សមតុល្យ : ឥណពន្ធ បង្ហាញតម្លៃសំណង់ អាគារដែលកំពុងមាន។

ចំណាំ : គណនីលេខ ២១៣ ត្រូវចែកទៅជាអនុគណនីសម្រាប់អាគារ ការរៀបចំកែលម្អអាគារ និងសម្រាប់សំណង់ផ្សេងៗទៀត។

**២៣-គណនី ហេដ្ឋារចនាសម្ព័ន្ធ " លេខ ២១៤ " :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាតម្លៃហេដ្ឋារចនាសម្ព័ន្ធដែលបានទិញ សាងសង់ ឬបានពីអំណោយ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាតម្លៃហេដ្ឋារចនាសម្ព័ន្ធ ដែលបានបញ្ចូលជាទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ឥណទាន : កត់ត្រាតម្លៃហេដ្ឋារចនាសម្ព័ន្ធ ដែលបានបន្ថយដោយលក់ ធ្វើអំណោយ ផ្ទេរ ឬជម្រះ

សមតុល្យ : ឥណាយិក បង្ហាញតម្លៃនៃហេដ្ឋារចនាសម្ព័ន្ធដែលកំពុងមាន។

ចំណាំ : គណនីលេខ ២១៤ ត្រូវចែកទៅជាអនុគណនី សម្រាប់បណ្តាញបង្ហូរទឹក និងអនាម័យ បណ្តាញអគ្គីសនី បណ្តាញជាពសាស្ត្រ និងសម្រាប់បណ្តាញផ្លូវថ្នល់ និងស្ពាន។

**២៤-គណនី ឋាបនកម្មបច្ចេកទេស សម្ភារៈ និងហត្ថូបករណ៍ " លេខ ២១៥ " :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាតម្លៃឋាបនកម្មបច្ចេកទេស សម្ភារៈ ហត្ថូបករណ៍ដែលបានពីការទិញ ពីអំណោយ ឬផ្ទេរមក។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាតម្លៃទ្រព្យសម្បត្តិជាឋាបនកម្មបច្ចេកទេស សម្ភារៈ ហត្ថូបករណ៍ដែលបានបញ្ចូលជាទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ឥណទាន : កត់ត្រាតម្លៃ ឋាបនកម្មបច្ចេកទេស សម្ភារៈ ហត្ថូបករណ៍ដែលបានបន្ថយដោយលក់ ធ្វើអំណោយ ជម្រះ ឬ បានផ្ទេរ

សមតុល្យ : ឥណាយិក បង្ហាញតម្លៃឋាបនកម្មបច្ចេកទេស សម្ភារៈ និងហត្ថូបករណ៍ដែលកំពុងមាន។

ចំណាំ : គណនីលេខ ២១៥ ត្រូវចែកទៅជាអនុគណនីសម្រាប់ឋាបនកម្មបច្ចេកទេស សម្ភារៈ និងគ្រឿងឧបករណ៍ (ហត្ថូបករណ៍)។

**២៥-គណនី អចលកម្មរូបីផ្សេងទៀត " លេខ ២១៨ " :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាតម្លៃអចលកម្មរូបីផ្សេងទៀត ដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានទិញសាងសង់ ឬបានពីអំណោយ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាតម្លៃអចលកម្មរូបីដែលបានបញ្ចូលជាទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ឥណទាន : កត់ត្រាតម្លៃអចលកម្មរូបីដែលបានបន្ថយដោយលក់ អំណោយ បានផ្ទេរ ឬជម្រះ

សមតុល្យ : ឥណាយិក បង្ហាញតម្លៃអចលកម្មរូបីផ្សេងទៀតដែលកំពុងមាន។

ចំណាំ : គណនីលេខ ២១៨ ត្រូវចែកទៅអនុគណនីសម្រាប់សម្ភារៈឧបករណ៍ដឹកជញ្ជូន សម្ភារៈឧបករណ៍ការិយាល័យ សម្ភារៈព័ត៌មានវិទ្យា និងទូរគមនាគមន៍ សង្ហារឹម និងអចលកម្មរូបីផ្សេងៗទៀត។

**២៦-គណនី រំលស់អចលកម្មអរូបី " លេខ ២៨០ " :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មអរូបីរបស់

រដ្ឋបាលថ្នាក់ក្រោមជាតិ។ គណនីនេះកត់ត្រាបដិភាគនឹងគណនីទាយជ្ជទានឲ្យដល់រំលស់អចលកម្ម។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មអរូបី ដែលបានជម្រះជាមួយតម្លៃអចលកម្ម

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មអរូបីក្នុងឆ្នាំ ដែលបានចាត់ជាចំណាយចរិកាចរន្ត

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់រំលស់អចលកម្មអរូបីបូកបន្ត។

ចំណាំ : - គណនីរំលស់អចលកម្មអរូបី ត្រូវចែកទៅជាអនុគណនីទៅតាមប្រភេទនៃអចលកម្មនីមួយៗ ដោយយកលេខលំដាប់ទី៣ នៃគណនីអចលកម្មអរូបី បន្ថែមពីក្រោយលេខ ២៨០។

- ការជំរះចំនួនទឹកប្រាក់ខាងឥណពន្ធ នៃគណនីរំលស់អចលកម្មអរូបី យោងលើការលក់ចេញ ការបោះបង់ចោល ការបាត់បង់ និងការផ្ទេរ។

- ករណីដែលចំនួនទឹកប្រាក់រំលស់បូកបន្តនៃអចលកម្មស្មើនឹងតម្លៃបញ្ចូលគឺត្រូវបញ្ឈប់ការធ្វើទាយជ្ជទានរំលស់។ ការជម្រះលុះត្រាតែអចលកម្មនោះឈប់ប្រើប្រាស់។

**២៧-គណនី រំលស់អចលកម្មរូបី "លេខ ២៨១":**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មរូបី (លើកលែងដីធ្លី) ដែលបានមកពីការទិញ ពីអំណោយ ឬពីឧបត្ថម្ភកធនវិនិយោគ។ គណនីនេះកត់ត្រាបដិភាគនឹងគណនីទាយជ្ជទានឲ្យដល់អចលកម្ម។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មរូបីដែលបានជម្រះជាមួយតម្លៃអចលកម្ម

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មរូបីក្នុងឆ្នាំ ដែលបានចាត់ជាចំណាយចរិកាចរន្ត

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់រំលស់អចលកម្មរូបីបូកបន្ត។

ចំណាំ : - គណនីរំលស់អចលកម្មរូបី ត្រូវចែកជាអនុគណនីទៅតាមប្រភេទនៃអចលកម្មនីមួយៗ ដោយយកលេខលំដាប់ទី៣ (គណនីអចលកម្មដែលមាន ៣ លេខ) បន្ថែមពីក្រោយលេខ ២៨១ ឬដោយយកលេខ ២ ខ្ទង់ចុងក្រោយនៃគណនីអចលកម្ម (គណនីអចលកម្មដែលមានលេខសម្គាល់ ៤ លេខ) បន្ថែមពីក្រោយលេខ ២៨១។

- អចលកម្មដែលបានធ្វើរំលស់ស្មើ នឹងតម្លៃបញ្ចូល ហើយនៅតែប្រើប្រាស់បាននោះ ត្រូវបញ្ឈប់ការធ្វើទាយជ្ជទានរំលស់ និងពុំទាន់ជាកម្មវត្ថុនៃការជម្រះឡើយ។

- ការជម្រះខាងឥណពន្ធនៃគណនីរំលស់ពេលលក់ចេញ បោះបង់ចោល បាត់បង់ និងផ្ទេរ។

**២៨-គណនី អ្នកផ្គត់ផ្គង់ "លេខ ៤០១":**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវទូទាត់សងទៅអ្នកផ្គត់ផ្គង់ដែលបានផ្តល់ទំនិញ សេវាកម្ម ការងារដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការកត់ត្រាចំនួនទឹកប្រាក់ទៅក្នុងគណនីនេះ ក្រោយពីការកាត់ពន្ធ ឬកាតព្វកិច្ចផ្សេងទៀតរួច។

ការកត់ត្រា:

ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់ដែលបានបើកផ្តល់ជូនអត្ថគាហក:

- កត់ត្រាចំនួនទឹកប្រាក់ដែលបានកាត់ទុកសម្រាប់ផ្ទេរចូលថវិការដ្ឋ ឬទូទាត់ទៅមុខសញ្ញាផ្សេង

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវសងទៅអ្នកផ្គត់ផ្គង់ទំនិញ សេវាការងារ យោងតាមអាណត្តិបើកប្រាក់ ឬបង្វែរពីគណនីផ្សេងមក

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បំណុលដែលត្រូវសងទៅអត្ថគាហកៈ។

ចំណាំ : - គណនីនេះពុំមានគំរូហត្ថលេខារបស់ម្ចាស់គណនីទេ គឺជាប្រភេទគណនីវង់ចាំ។

- គណនីនេះត្រូវចែកទៅជាអនុគណនីសម្រាប់បំណុលឆ្នាំចាស់ និងឆ្នាំថ្មី។

**២៩-គណនី សាច់ប្រាក់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលពីរាជរដ្ឋាភិបាល "លេខ ៤១០":**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្តប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលពីរាជរដ្ឋាភិបាល ដោយយោងតាមការផ្តល់វិភាជន៍ថវិកា ឬកិច្ចព្រមព្រៀងផ្សេងៗ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនសាច់ប្រាក់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលពីរាជរដ្ឋាភិបាល

ឥណទាន : កត់ត្រាចំនួនសាច់ប្រាក់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានទទួលពីរាជរដ្ឋាភិបាល

សមតុល្យ : ឥណាយិក បង្ហាញចំនួនសាច់ប្រាក់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលពីរាជរដ្ឋាភិបាល។

ចំណាំ : - គណនីនេះត្រូវចែកទៅជាអនុគណនី សាច់ប្រាក់ដែលក្រុង ស្រុក ខណ្ឌត្រូវទទួលពីរាជរដ្ឋាភិបាល និងអនុគណនី សាច់ប្រាក់ដែលឃុំ សង្កាត់ត្រូវទទួលពីរាជរដ្ឋាភិបាល។

- អនុគណនីទាំងនេះ ត្រូវចែកជាអនុគណនីរងប្រើសម្រាប់ឆ្នាំចាស់ និងឆ្នាំថ្មី។

**៣០-គណនី អតិថិជន ( ចំណូលមិនមែនសារពើពន្ធ ) "លេខ ៤១៣":**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើ សម្រាប់កត់ត្រាចំនួនទឹកប្រាក់បំណុលមិនមែនសារពើពន្ធដែលត្រូវប្រមូលពីសហគ្រាស ក្រុមហ៊ុន និងរូបវន្តបុគ្គល។ ចំនួនទឹកប្រាក់ដែលត្រូវកត់ត្រា គឺយោងតាមរបាយការណ៍ឬកិច្ចសន្យាពីអង្គភាព ដែលមានការពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលនេះ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលមិនមែនសារពើពន្ធដែលត្រូវប្រមូល ( ខាងឥណពន្ធ នៃគណនីនេះ បដិភាគនឹងខាងឥណទាននៃគណនីចំណូលត្រូវប្រមូលបានកត់ត្រាទុកមុន )

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណូលមិនមែនសារពើពន្ធដែលសហគ្រាស ក្រុមហ៊ុន និងរូបវន្តបុគ្គលបានសង

- កត់ត្រាចំនួនទឹកប្រាក់ចំណូលត្រូវបានបន្ថយ ឬ ជម្រះ ( ខាងឥណទាននៃគណនីនេះ បដិភាគនឹងខាង ឥណពន្ធនៃគណនី ចំណូលត្រូវប្រមូលបានកត់ត្រាទុកមុន )

- ទន្ទឹមនឹងលេខនាខាងឥណទាន នៃគណនីនេះត្រូវមានលេខនាទី២ គឺកត់ត្រាខាង ឥណពន្ធ គណនីហិរញ្ញវត្ថុ និងខាងឥណទាន គណនីចំណូលថវិកា ដែលពាក់ព័ន្ធ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណូលមិនមែនសារពើពន្ធដែលត្រូវប្រមូល។

ចំណាំ : រាល់លើកនៃការបង់ប្រាក់ រតនាគាររាជធានី ខេត្តត្រូវធ្វើការវិភាគ រួចកត់ត្រាជាចំណូលក្នុងឆ្នាំ ឬបន្ថយបំណុលឆ្នាំមុន។

**៣១-គណនី ប្រាក់បៀវត្ស និងលាភការត្រូវសង "លេខ ៤២១":**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់បៀវត្ស លាភការដែលត្រូវសងនិង បានបើកផ្តល់តាមអាណត្តិបើកប្រាក់។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនប្រាក់បៀវត្ស និងលាភការដែលបានបើកផ្តល់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បៀវត្ស និងលាភការដែលត្រូវបើកផ្តល់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ប្រាក់បៀវត្ស និងលាភការដែលពុំទាន់បានបើកផ្តល់ជូនរដ្ឋបាល បាលថ្នាក់ក្រោមជាតិ។

<u>ចំណាំ</u> : គណនីលេខ ៤២១ មានគំរូហត្ថលេខារបស់ម្ចាស់គណនីដែលជាភ្នាក់ងារបើកផ្តល់ហើយត្រូវចែកទៅជាអនុគណនីសម្រាប់ឆ្នាំចាស់ និងឆ្នាំថ្មី។

**៣២-គណនី សោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេងៗត្រូវសង "លេខ ៤២២":**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្តប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់សោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេងៗដែលត្រូវសងទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្ទាល់តាមរយៈភ្នាក់ងារបើកផ្តល់ ឬរដ្ឋទេយ្យករបុរេប្រទាន។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានបើកផ្តល់ជាសាច់ប្រាក់ មូលប្បទានបត្រ ឬដោយបង្វែរ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់សោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេងៗត្រូវសងទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយយោងតាមអាណត្តិបើកប្រាក់

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បេសកកម្ម និងសោហ៊ុយផ្សេងៗត្រូវសងដែលពុំទាន់បានបើកផ្តល់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ។

<u>ចំណាំ</u> : គណនីលេខ ៤២២ ពុំចាំបាច់មានគំរូហត្ថលេខារបស់ម្ចាស់គណនី ហើយត្រូវចែកជាអនុគណនីសម្រាប់ឆ្នាំចាស់ និងឆ្នាំថ្មី។

**៣៣-គណនី ទំនាក់ទំនងរវាងថវិការាជធានី ខេត្ត និងថវិកាក្រុង ស្រុក ខណ្ឌ "លេខ ៤៥៧":**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលមានការពាក់ព័ន្ធនឹងចំណូលចំណាយថវិកាក្រុង ស្រុក ខណ្ឌដែលត្រូវប្រើប្រាស់។ គណនីនេះប្រើសម្រាប់កិច្ចបញ្ជិកាក្នុងគណនេយ្យថវិការាជធានី ខេត្ត និងក្នុងគណនេយ្យថវិកាក្រុង ស្រុក ខណ្ឌ ដោយកត់ត្រាបញ្ច្រាសគ្នា។

ការកត់ត្រា:

ឥណពន្ធ :
- កត់ត្រាចំនួនទឹកប្រាក់ ស្មើនឹងចំណូលថវិការបស់ក្រុង ស្រុក ខណ្ឌដែលត្រូវបញ្ចូលទៅក្នុងគណនីប្រាក់បញ្ញើរបស់រាជធានី ខេត្តនៅរតនាគារ (កិច្ចបញ្ជិការបស់គណនេយ្យថវិកាក្រុង ស្រុក ខណ្ឌ)
- កត់ត្រាចំនួនទឹកប្រាក់ស្មើនឹងចំណាយថវិការបស់ក្រុង ស្រុក ខណ្ឌដែលត្រូវកាត់កងពីគណនីប្រាក់បញ្ញើរបស់រាជធានី ខេត្ត (កិច្ចបញ្ជិការបស់គណនេយ្យថវិការាជធានី ខេត្ត)

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ស្មើនឹងចំណាយថវិកាបេស់ក្រុង ស្រុក ខណ្ឌ ដែលត្រូវកាត់កងពីគណនីប្រាក់បញ្ញើរបស់រាជធានី ខេត្ត (កិច្ចបញ្ជិការបស់គណនេយ្យថវិកាក្រុង ស្រុក ខណ្ឌ)

- កត់ត្រាចំនួនទឹកប្រាក់ស្មើនឹងចំណូលថវិការបស់ក្រុង ស្រុក ខណ្ឌ ដែលត្រូវបញ្ចូលទៅក្នុងគណនីប្រាក់បញ្ញើរបស់រាជធានី ខេត្ត (កិច្ចបញ្ជិការបស់គណនេយ្យថវិការាជធានី ខេត្ត)

សមតុល្យ : - ឥណពិក បង្ហាញចំនួនទឹកប្រាក់ដែលក្រុង ស្រុក ខណ្ឌត្រូវសង (គណនេយ្យថវិកាក្រុង ស្រុក ខណ្ឌ)

- ឥណទាយី បង្ហាញចំនួនទឹកប្រាក់ដែលក្រុង ស្រុក ខណ្ឌត្រូវសង (គណនេយ្យថវិការាជធានី ខេត្ត)។

ចំណាំ : គណនីលេខ ៤៥៧ ជាគណនីចំលង និងបង្ហាញអំពីទំនាក់ទំនងជាមួយគណនីប្រាក់បញ្ញើថវិការបស់រាជធានី ខេត្ត ដែលប្រើរួមគ្នារវាងរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ហើយមានចលនានិងសមតុល្យផ្ទុះបញ្ជាំងបញ្ច្រាសគ្នា។

**៣៤-គណនី ប្រាក់តម្កល់ធានាលើទីផ្សារសាធារណៈ "លេខ ៤៦២" :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលអ្នកផ្គត់ផ្គង់ អ្នកម៉ៅការបានបង់សម្រាប់តម្កល់ធានាការដេញថ្លៃនិងធានាលើការផ្គត់ផ្គង់សម្ភារៈ សេវាកម្ម សាងសង់ ដោយយោងតាមកិច្ចសន្យា។

ការកត់ត្រាៈ

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់តម្កល់ធានាដែលបានសងទៅអ្នកដែលបានបង់ប្រាក់វិញ

- កត់ត្រាចំនួនទឹកប្រាក់តម្កល់ធានាដែលបានផ្ទេរចូលថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់តម្កល់ធានាដែលបានទទួល

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់តម្កល់ធានាលើទីផ្សារសាធារណៈ ដែលត្រូវសង។

ចំណាំ : នៅពេលដកប្រាក់តម្កល់ធានាទៅវិញ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវចេញលិខិតបញ្ជាក់មករតនាគារដើម្បីបើកផ្តល់ប្រាក់។

**៣៥-គណនី ឥណពិកផ្សេងៗ "លេខ ៤៦៣" :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ត្រូវទារផ្សេងៗក្រៅពីពន្ធដារនិងពន្ធគយ ឬត្រូវដោះស្រាយ។ គណនីលេខ ៤៦៣ ជាប្រភេទគណនីចម្លង។



ការកត់ត្រាៈ

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ផ្សេងៗត្រូវទារ ឬត្រូវដោះស្រាយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ផ្សេងៗបានសង ឬបានដោះស្រាយ

សមតុល្យ : ឥណពិក បង្ហាញចំនួនទឹកប្រាក់ផ្សេងៗត្រូវទារ ឬត្រូវដោះស្រាយ។

**៣៦-គណនី ឥណទាយីផ្សេងៗ "លេខ ៤៦៥" :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ត្រូវទារផ្សេងៗក្រៅពីបំណុលត្រូវសងទៅឱ្យអ្នកផ្គត់ផ្គង់ និងចំនួនទឹកប្រាក់ត្រូវដោះស្រាយ។ គណនីលេខ ៤៦៥ ជាប្រភេទគណនីចម្លង។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ផ្សេងៗបានសង ឬបានដោះស្រាយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ផ្សេងៗត្រូវសង ឬត្រូវដោះស្រាយ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ផ្សេងៗត្រូវសង ឬត្រូវដោះស្រាយ។

**៣៧-គណនី ប្រាក់ចំណូលពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអនុវត្តគម្រោង " លេខ ៤៦៦ " :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានពីការចូលរួមរបស់ប្រជាពលរដ្ឋលើគម្រោង ដែលពុំទាន់បានចាត់ចែងទៅជាចំណូលថវិកា ឬត្រូវផ្ទេរទៅមុខសញ្ញាផ្សេង។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលពីការចូលរួមរបស់ប្រជាពលរដ្ឋ ដែលបានផ្ទេរទៅជាចំណូលថវិកា ឬផ្ទេរទៅមុខសញ្ញាផ្សេង

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលពីការចូលរួមរបស់ប្រជាពលរដ្ឋ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលពីការចូលរួមរបស់ប្រជាពលរដ្ឋ ដែលពុំទាន់បានចាត់ចែង។

**៣៨-គណនី ចំណូលផ្សេងៗរង់ចាំដោះស្រាយ " លេខ ៤៧០ " :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលផ្សេងៗ ឬចំនួនទឹកប្រាក់ដែលត្រូវបង្វែរទៅគណនីផ្សេងទៀត។ គណនីលេខ ៤៧០ ជាប្រភេទគណនីរង់ចាំ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលបានដោះស្រាយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលរង់ចាំដោះស្រាយ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលរង់ចាំការដោះស្រាយ ។

**៣៩-គណនី ចំណាយផ្សេងៗរង់ចាំដោះស្រាយ " លេខ ៤៧២ " :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយផ្សេងៗ ដែលត្រូវដោះស្រាយ។ គណនីលេខ ៤៧២ ជាប្រភេទគណនីរង់ចាំ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយបានដោះស្រាយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយរង់ចាំការដោះស្រាយ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណាយរង់ចាំការដោះស្រាយ។

**៤០-គណនី រដ្ឋទេយ្យករចំណូល " លេខ ៤៧៧ " :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលរបស់រដ្ឋទេយ្យករចំណូល របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករចំណូលបានផ្ទេរចូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូល ដែលរដ្ឋទេយ្យករបានបង់ជាសាច់ប្រាក់ មូលប្បទានបត្រ ឬបង្វែរ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករចំណូលពុំទាន់បានផ្ទេរចូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។

<u>ចំណាំ</u> : គណនីលេខ ៤៧៧ ត្រូវមានគំរូហត្ថលេខារបស់ម្ចាស់គណនី (រដ្ឋទេយ្យករចំណូល) និងត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំ។

**៤១-គណនី ចំណូលត្រូវប្រមូលបានកត់ត្រាទុកមុន "លេខ ៤៨២" :**

គណនីនេះបើកនៅតេនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលមិនមែនសារពើពន្ធដែលត្រូវទារពីអាជីវករ។ គណនីលេខ ៤៨២ កត់ត្រាបដិភាគជាមួយនឹងគណនីអតិថិជន (លេខ ៤១៣) ដោយយោងតាមរបាយការណ៍ឬកិច្ចសន្យារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ការកត់ត្រា:

ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់ដែលប្រមូលបាន ដោយបដិភាគនឹងគណនីអតិថិជន

- កត់ត្រាចំនួនទឹកប្រាក់មិនមែនសារពើពន្ធដែលបានជម្រះដោយបន្ធូរបន្ថយ ឬលប់ចោល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់មិនមែនសារពើពន្ធដែលត្រូវប្រមូល ដោយបដិភាគនឹងគណនី អតិថិជន (លេខ ៤១៣)

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់មិនមែនសារពើពន្ធដែលត្រូវប្រមូល។

<u>ចំណាំ</u> : ការកត់ត្រាខាងឥណទានគណនី លេខ ៤៨២ ទន្ទឹមនឹងលេខនាកត់ត្រាចំណូលពិតប្រាកដ ដែលប្រមូលបាន (ឥណពន្ធ គណនីហិរញ្ញវត្ថុ និងឥណទាន គណនីចំណូលថវិកា)។

**៤២-គណនី ប្រាក់បញ្ញើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅរតនាគារ "លេខ ៥១៥" :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយ មូលនិធិដែលរដ្ឋបាលថ្នាក់ក្រោមជាតិផ្ញើនៅរតនាគារ។ ចំនួនទឹកប្រាក់ដែលកត់ត្រាទៅក្នុងគណនីនេះ គឺមានទំនាក់ទំនងជាមួយនឹងចំណូល ចំណាយថវិកា ប្រាក់តម្កល់ជានាលើទីផ្សារសាធារណៈ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានដកជាចំណាយថវិកា ឬចំណាយសម្រាប់មុខសញ្ញាផ្សេងទៀត។

សមតុល្យ : ឥណាយិក បង្ហាញចំនួនមូលនិធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ កំពុងមាននៅរតនាគារ។

<u>ចំណាំ</u> :- គណនីនេះត្រូវចែកជាអនុគណនី សម្រាប់ថវិការាជធានី ខេត្ត ថវិកាក្រុង ស្រុក ខណ្ឌ និងថវិកាឃុំ សង្កាត់។

- គណនីលេខ ៥១៥ ឆ្លុះបញ្ចាំងប្រតិបត្តិការបញ្ច្រាសនឹងគណនីប្រាក់បញ្ញើថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (លេខ ៤៤២) នៃប្លង់គណនេយ្យរដ្ឋ។

**៤៣-គណនី បុរេប្រទានពីរតនាគារ "លេខ ៥១៩" :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានទទួលពីរតនាគារ យោងតាមការសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬរតនាគារជាតិ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានទូទាត់បុរេប្រទាន ដោយកាត់ពីគណនីប្រាក់បញ្ញើនៅរតនាគារ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានបុរេប្រទានពីរតនាគារដោយបញ្ចូលទៅក្នុងគណនីប្រាក់បញ្ញើនៅរតនាគារ

សមតុល្យ : ឥណទាយី បង្ហាញអំពីចំនួនទឹកប្រាក់បុរេប្រទាន ដែលរដ្ឋបាលថ្នាក់ក្រោមជាតិពុំទាន់បានទូទាត់។

<u>ចំណាំ</u> : រាល់ប្រាក់បុរេប្រទានដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានទទួលត្រូវឆ្លងកាត់គណនីប្រាក់បញ្ញើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅរតនាគារ។

**៤៤-គណនី រដ្ឋទេយ្យករបុរេប្រទាន (ថវិកាមិនមែនកម្មវិធី) "លេខ ៥៤៣" :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្តប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានសម្រាប់ថវិកាមិនមែនកម្មវិធី ដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានទទួលពីរតនាគារតាមរយៈរដ្ឋទេយ្យករបុរេប្រទាន។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានបើកផ្តល់ទៅរដ្ឋទេយ្យករបុរេប្រទានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករបុរេប្រទានបានទូទាត់ជាអាណត្តិបើកប្រាក់
- កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករបុរេប្រទានបានបង់ចូលរតនាគារវិញ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករបុរេប្រទានពុំទាន់បានទូទាត់ជាមួយរតនាគារ។

<u>ចំណាំ</u> : - ការគណនា ការបង្កើន ឬការបន្ថយកំរិតកំណត់រដ្ឋទេយ្យបុរេប្រទាន ថវិកាមិនមែនកម្មវិធី គឺធ្វើនៅក្រៅកិច្ចបញ្ជីកាគណនេយ្យ។
- គណនី លេខ ៥៤៣ ត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំ។

**៤៥-គណនី រដ្ឋទេយ្យករបុរេប្រទាន (ថវិកាកម្មវិធី) "លេខ ៥៤៤" :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្តប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានសម្រាប់ថវិកាតាមកម្មវិធី ដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានទទួលពីរតនាគារតាមរយៈរដ្ឋទេយ្យករបុរេប្រទាន។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានបើកផ្តល់ទៅរដ្ឋទេយ្យករបុរេប្រទានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករបុរេប្រទានបានទូទាត់ជាអាណត្តិបើកប្រាក់
- កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករបុរេប្រទានបានបង់ចូលរតនាគារវិញ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករបុរេប្រទានពុំទាន់បានទូទាត់ជាមួយរតនាគារ។

<u>ចំណាំ</u> : - ការគណនា ការបង្កើន ឬការបន្ថយកំរិតកំណត់រដ្ឋទេយ្យបុរេប្រទាន ថវិកាតាមកម្មវិធី គឺធ្វើនៅក្រៅកិច្ចបញ្ជិកាគណនេយ្យ។
- គណនី លេខ ៥៤៤ ត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំ។

**៤៦-គណនី សម្ភារៈផ្គត់ផ្គង់ ថែទាំ "លេខ ៦០១" :**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការទិញសម្ភារៈផ្គត់ផ្គង់ ថែទាំ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៦០១ ត្រូវចែកទៅជាអនុគណនី សម្រាប់ចំណាយទិញសម្ភារៈផ្គត់ផ្គង់សំអាត និង អនាម័យ ទិញសម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអាគារ ទិញសម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំផ្លូវថ្នល់ ផ្លូវលំ ស្ពាន និងលូ ទិញសម្ភារៈផ្គត់ផ្គង់ថែទាំ សម្ភារៈឧបករណ៍ និងទិញប្រេងឥន្ធនៈ និងប្រេងរំអិល។

**៤៧-គណនី សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល "លេខ ៦០២" :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការទិញសម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៦០២ ត្រូវចែកទៅជាអនុគណនី សម្រាប់ចំណាយទិញសម្ភារៈការិយាល័យ និងការបោះពុម្ព ទិញសៀវភៅមើល និងឯកសារ និងសម្រាប់ទិញសម្ភារៈផ្សេងៗ។

**៤៨-គណនី ស្បៀងអាហារ "លេខ ៦០៣" :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការទិញស្បៀងអាហារ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៦០៣ ត្រូវចែកទៅជាអនុគណនី សម្រាប់ចំណាយទិញស្បៀង។

**៤៩-គណនី សំលៀកបំពាក់ និងការតុបតែង "លេខ ៦០៤" :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការទិញសំលៀកបំពាក់ និងការតុបតែងលំអ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៦០៤ ត្រូវចែកទៅជាអនុគណនី សម្រាប់ចំណាយទិញឯកសណ្ឋាន ទិញសំលៀកបំពាក់ការពារសុវត្ថិភាព ទិញមេដាយ (គ្រឿងឥស្សរិយយស) និងសម្រាប់ទិញសំលៀកបំពាក់ការតុបតែងផ្សេងៗទៀត។

**៥០-គណនី សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ "លេខ ៦០៥" :**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការទិញសម្ភារៈ សង្ហារឹម និងសម្ភារៈបរិក្ខារ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៦០៥ ត្រូវចែកទៅជាអនុគណនីសម្រាប់ចំណាយទិញសម្ភារៈនិងបរិក្ខារ ទិញសង្ហារឹម ទិញសម្ភារៈប្រើប្រាស់ ទិញសម្ភារៈនិងឧបករណ៍ដឹកជញ្ជូន និងសម្រាប់ទិញសម្ភារៈផ្សេងៗទៀត។

**៥១-គណនី ថាមពល និងទឹក "លេខ ៦០៦" :**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការទូទាត់ការប្រើប្រាស់ថាមពល និងការប្រើប្រាស់ទឹក។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៦០៦ ត្រូវចែកទៅជាអនុគណនី សម្រាប់ចំណាយលើអគ្គិសនី ចំណាយលើថ្លៃទឹក និងចំណាយលើការទិញថាមពលផ្សេងៗទៀត។

**៥២-គណនី សម្ភារៈផ្គត់ផ្គង់ផ្សេងៗ "លេខ ៦០៨" :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការទិញសម្ភារៈផ្គត់ផ្គង់ផ្សេងៗទៀត ដែលពុំបានរៀបរាប់ខាងលើ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**៥៣-គណនី កិច្ចសន្យានៃការផ្ដល់សេវាជាមួយសហគ្រាស "លេខ ៦១១":**

គណនីនេះបើកនៅរតនាគារាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការទូទាត់ជូនទៅសហគ្រាស ក្រុមហ៊ុន ឬអាជីវករដែលបានផ្ដល់សេវាកម្មដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**៥៤-គណនី ការជួលមធ្យោបាយដឹកជញ្ជូន "លេខ ៦១២":**

គណនីនេះ បើកនៅរតនាគារាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការទូទាត់ថ្លៃឈ្នួលមធ្យោបាយដឹកជញ្ជូន។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**៥៥-គណនី ថ្លៃឈ្នួល និងបន្ទុក (អសង្ហារឹម) "លេខ ៦១៣":**

គណនីនេះបើកនៅរតនាគារាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការទូទាត់ថ្លៃឈ្នួលទីតាំង ស្នាក់ការរដ្ឋបាល។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**៥៦-គណនី សោហ៊ុយបណ្ដុះបណ្ដាលបុគ្គលិក "លេខ ៦១៤":**

គណនីនេះបើកនៅរតនាគារាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការបណ្ដុះបណ្ដាលបុគ្គលិក។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**៥៧-គណនី ការថែទាំ និងជួសជុល "លេខ ៦១៥":**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការថែទាំ និងជួសជុល។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៦១៥ ត្រូវចែកទៅជាអនុគណនី សម្រាប់ចំណាយលើការថែទាំដីធ្លី សួនច្បារ រៀបជាជួរ ការថែទាំ ទីផ្សារនិងសត្តឃាតដ្ឋាននិងអាគារសាធារណៈ ការថែទាំ ជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងប្រព័ន្ធលូ ការថែទាំបណ្តាញផ្សេងៗ ការថែទាំនិងជួសជុលសម្ភារៈការិយាល័យសម្ភារៈព័ត៌មានវិទ្យា និងទូរគមនាគមន៍ ការថែទាំនិងជួសជុលមធ្យោបាយដឹកជញ្ជូន និងសម្រាប់ការថែទាំនិងជួសជុលសម្ភារៈឧបករណ៍បច្ចេកទេស។

**៥៨-គណនី សោហ៊ុយធានារ៉ាប់រង "លេខ ៦១៦":**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការបង់សោហ៊ុយធានារ៉ាប់រងផ្សេងៗ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**៥៩-គណនី សោហ៊ុយសិក្សាសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និងសោហ៊ុយនៃការប្រើប្រាស់សិទ្ធិ "លេខ ៦១៧":**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការសិក្សា ពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និងសោហ៊ុយនៃការប្រើប្រាស់សិទ្ធិ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៦១៧ ត្រូវចែកទៅជាអនុគណនី សម្រាប់ចំណាយលើសោហ៊ុយសិក្សា ពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ និងសម្រាប់សំណង់ផ្នែកស៊ីវិល។

**៦០-គណនី សោហ៊ុយដឹកជញ្ជូន "លេខ ៦១៨" :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើសោហ៊ុយដឹកជញ្ជូនសម្ភារៈ និងទំនិញ។

ការកត់ត្រាៈ

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៦១៨ ត្រូវចែកទៅជាអនុគណនី សម្រាប់ចំណាយលើថ្លៃដឹកជញ្ជូនសម្ភារៈ និងទំនិញ (ដឹកបញ្ញើប្រៃសណីយ៍ជាដើម)។

**៦១-គណនី បុគ្គលិកខាងក្រៅ "លេខ ៦២១" :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការទូទាត់ប្រាក់បំណាច់ លាភការ របស់បុគ្គលិកក្រៅពីបុគ្គលិកក្របខ័ណ្ឌរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការកត់ត្រាៈ

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៦២១ ត្រូវចែកទៅជាអនុគណនី សម្រាប់ចំណាយលើភ្នាក់ងារជាតិជាប់កិច្ចសន្យា សម្រាប់ភ្នាក់ងារបរទេសជាប់កិច្ចសន្យា និងសម្រាប់បុគ្គលិកសមូហភាពសាធារណៈផ្សេងៗ។

**៦២-គណនី ទំនាក់ទំនងសាធារណៈ និងការផ្សព្វផ្សាយ "លេខ ៦២២" :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើទំនាក់ទំនងសាធារណៈ និងការផ្សព្វផ្សាយ។

ការកត់ត្រាៈ

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៦២២ ត្រូវចែកទៅជាអនុគណនី សម្រាប់ចំណាយសោហ៊ុយទទួលភ្ញៀវជាតិ សោហ៊ុយទទួលភ្ញៀវបរទេស ប្រជុំសិក្ខាសាលា និងសន្និសីទ សោហ៊ុយពិធីបុណ្យ ការទិញវត្ថុអនុស្សាវរីយ៍ក្នុង និងក្រៅប្រទេស សោហ៊ុយសម្រាប់ការតាំងពិព័រណ៍នៅក្នុងនិងក្រៅប្រទេស និងសម្រាប់ការឃោសនា និងផ្សព្វផ្សាយព័ត៌មានសាធារណៈ។

**៦៣-គណនី សោហ៊ុយជាវសារព័ត៌មាន និងឯកសារ "លេខ ៦២៣":**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការទូទាត់ថ្លៃសារព័ត៌មាន និងទិញឯកសារ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**៦៤-គណនី ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស "លេខ ៦២៤":**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការទូទាត់សោហ៊ុយធ្វើដំណើរ ប្រាក់បេសកកម្ម និងសោហ៊ុយស្នាក់នៅក្នុងប្រទេស។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

<u>ចំណាំ</u> : គណនីលេខ ៦២៤ត្រូវចែកទៅជាអនុគណនី សម្រាប់សោហ៊ុយដឹកជញ្ជូន សោហ៊ុយបេសកកម្ម និងសម្រាប់សោហ៊ុយស្នាក់នៅ។

**៦៥-គណនី ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស "លេខ ៦២៥":**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការទូទាត់សោហ៊ុយ ធ្វើដំណើរបេសកកម្ម និងសោហ៊ុយស្នាក់នៅក្រៅប្រទេស។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពាយិក បង្ហាញពីចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>ចំណាំ</u> : គណនីលេខ ៦២៥ ត្រូវចែកទៅជាអនុគណនី សម្រាប់សោហ៊ុយដឹកជញ្ជូន សោហ៊ុយបេសកកម្ម និងសម្រាប់សោហ៊ុយស្នាក់នៅ។

**៦៦-គណនី សោហ៊ុយទូរគមនាគមន៍ ទូរស័ព្ទ តេឡិច និងទូរសារប្រៃសណីយ៍ "លេខ ៦២៦":**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការទូទាត់សេវាទូរគមនាគមន៍ ទូរស័ព្ទ តេឡិច និងទូរសារប្រៃសណីយ៍។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញអំពីចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៦២៦ ត្រូវចែកទៅជាអនុគណនី សម្រាប់ចំណាយសោហ៊ុយប្រៃសណីយ៍ និងសម្រាប់ចំណាយសោហ៊ុយទូរគមនាគមន៍។

**៦៧-គណនី សោហ៊ុយធនាគារ "លេខ ៦២៧" :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើសេវាធនាគារ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**៦៨-គណនី សោហ៊ុយផ្សេងៗ "លេខ ៦២៨" :**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការទូទាត់សោហ៊ុយផ្សេងៗទៀត។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**៦៩-គណនី លតាបត្រ "លេខ ៦៣១" :**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការបង់ពន្ធលតាបត្រ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**៧០-គណនី បន្ទុកពន្ធប្រថាប់ត្រា "លេខ ៦៣៣" :**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការបង់ពន្ធប្រថាប់ត្រា។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**៧១-គណនី លាភការ និងប្រាក់បំណាច់នៃអំណាចសាធារណៈ "លេខ ៦៤១":**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើលាភការ និងប្រាក់បំណាច់នៃអំណាចសាធារណៈ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ឬកត់ត្រាបន្ថយទឹកប្រាក់សំណោះចំណាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៦៤១ ត្រូវបែកទៅជាអនុគណនី សម្រាប់ប្រាក់បំណាច់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, ប្រាក់បំណាច់អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លាភការទីប្រឹក្សានិងលាភការបេសកជន។

**៧២-គណនី លាភការ និងប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ "លេខ ៦៤២":**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើលាភការ និងប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ឬកត់ត្រាបន្ថយទឹកប្រាក់សំណោះចំណាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៦៤២ ត្រូវបែកទៅជាអនុគណនី សម្រាប់ចំណាយបៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ប្រាក់បំណាច់ម៉ោងបន្ថែម ប្រាក់បំណាច់តំបន់ ប្រាក់បំណាច់ទទួលខុសត្រូវ និងប្រាក់បំណាច់ការងារធ្ងន់ និងប៉ះពាល់សុខភាព។

**៧៣-គណនី រង្វាន់ និងប្រាក់បំណាច់ផ្សេងៗទៀត "លេខ ៦៤៣":**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើរង្វាន់ និងប្រាក់បំណាច់ផ្សេងៗទៀត។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ឬកត់ត្រាបន្ថយទឹកប្រាក់សំណេះចំណាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៦៤៣ ត្រូវចែកទៅជាអនុគណនីសម្រាប់កន្សោមអាទិភាព ប្រាក់បំណាច់សម្រាប់ប្រឡង ប្រឡងប្រជែង រង្វាន់ ប្រាក់បំណាច់បុគ្គលិកក្រសួងផ្សេងៗ និងប្រាក់បំណាច់ផ្សេងៗទៀត។

**៧៤-គណនី លាភការ និងប្រាក់បំណាច់បុគ្គលិកមិនមែនក្របខ័ណ្ឌ និងបុគ្គលិកអណ្តែត " លេខ ៦៤៤ " :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើលាភការ និងប្រាក់បំណាច់ បុគ្គលិកមិនមែនក្របខ័ណ្ឌ និងបុគ្គលិកអណ្តែត។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ឬកត់ត្រាបន្ថយទឹកប្រាក់សំណេះចំណាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៦៤៤ ត្រូវចែកទៅជាអនុគណនីសម្រាប់បៀវត្សមូលដ្ឋានបុគ្គលិកមិនមែនក្របខ័ណ្ឌ លាភការផ្សេងៗទៀតបុគ្គលិកមិនមែនក្របខ័ណ្ឌ បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត លាភការផ្សេងៗទៀតបុគ្គលិកអណ្តែត និងប្រាក់ឧបត្ថម្ភភូមិ។

**៧៥-គណនី ប្រាក់វិភាជន៍សង្គម " លេខ ៦៤៥ " :**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើប្រាក់វិភាជន៍សង្គម។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ឬកត់ត្រាបន្ថយទឹកប្រាក់សំណេះចំណាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៦៤៥ ត្រូវចែកជាអនុគណនី សម្រាប់ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ មន្ត្រីមានជំងឺ និងឧបត្ថម្ភអ្នកសំរាលកូន មរណភាព ឧបត្ថម្ភនិវត្តជន ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ គ្រោះថ្នាក់ការងារ និងទព្វលភាព ឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីរាជការ និងប្រាក់វិភាជន៍សង្គមផ្សេងៗទៀត។

**៧៦-គណនី ឧបត្ថម្ភធនដល់រដ្ឋបាលដែនដី " លេខ ៦៥១ " :**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាល

ថ្នាក់ក្រោមជាតិ លើការផ្តល់ឧបត្ថម្ភកធនដល់រដ្ឋបាលដែនដី។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៦៥១ ត្រូវចែកជាអនុគណនីសម្រាប់ឧបត្ថម្ភកធនដល់ក្រុង ស្រុក ខណ្ឌ ឧបត្ថម្ភដល់ឃុំ សង្កាត់ និងសម្រាប់ឧបត្ថម្ភដល់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

**៧៧-គណនី ជំនួយសង្គម និងប្រាក់វិភាជន៍ "លេខ ៦៥២":**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការជួយឧបត្ថម្ភកធនដល់កិច្ចការសង្គម និងប្រាក់វិភាជន៍។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៦៥២ ត្រូវចែកជាអនុគណនី សម្រាប់ជួយប្រជាជនក្រីក្រសំរាកពេទ្យ ជួយជនរងគ្រោះដោយធម្មជាតិ និងសម្រាប់ចំណាយសង្គមផ្សេងៗទៀត។

**៧៨-គណនី ឧបត្ថម្ភកធនដល់អង្គភាពមានលក្ខណៈសង្គម និងវប្បធម៌ "លេខ ៦៥៣":**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការផ្តល់ឧបត្ថម្ភកធនដល់អង្គភាព មានលក្ខណៈសង្គម និងវប្បធម៌។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៦៥៣ ត្រូវចែកជាអនុគណនី សម្រាប់ឧបត្ថម្ភមណ្ឌលកុមារកំព្រា ឧបត្ថម្ភសហគមន៍ កីឡា និងវប្បធម៌ ឧបត្ថម្ភកាកបាទក្រហម និងសម្រាប់ឧបត្ថម្ភដល់អង្គការមូលដ្ឋាននិងគាំទ្រកម្មវិធីផ្សេងៗ។

**៧៩-គណនី ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច "លេខ ៦៥៤":**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**៨០-គណនី វិភាគទានដល់អង្គការអន្តរជាតិនានា "លេខ ៦៥៦" :**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការផ្តល់វិភាគទានដល់អង្គការអន្តរជាតិនានា។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>ចំណាំ</u> : គណនីលេខ ៦៥៦ ត្រូវចែកជាអនុគណនីសម្រាប់ឧបត្ថម្ភដល់អង្គការអន្តរជាតិផ្សេងៗ។

**៨១-គណនី ឥណទេយ្យដែលទទួលស្គាល់តែទារមិនបាន "លេខ ៦៧១" :**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើឥណទេយ្យ ឬចំណាយផ្សេងៗដែលទារមិនបានហើយបានជម្រះ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចាត់ជាចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**៨២-គណនី តម្លៃគណនេយ្យនៃចំណែកសកម្មបានលក់ (តម្លៃនៅសល់) "លេខ ៦៧៥" :**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើតម្លៃគណនេយ្យនៃចំណែកសកម្មបានលក់ (តម្លៃនៅសល់)។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចាត់ជាចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**៨៣-គណនី ទាយជ្ជទានអោយដល់វិលស់អចលកម្មអរូបី "លេខ ៦៨១" :**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្តប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើទាយជ្ជទានអោយដល់វិលស់អចលកម្មអរូបី។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់រំលស់បានចាត់ជាចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**៨៤-គណនី ទាយជ្ជទានអោយដល់រំលស់អចលកម្មរូបី " លេខ ៦៨២ " :**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើទាយជ្ជទានអោយដល់រំលស់អចលកម្មរូបី។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់រំលស់បានចាត់ជាចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយថវិកាបូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

**<u>ចំណាំ:</u>**

**ចំពោះការបន្ថយចំណាយថវិកាលើគណនីលេខ ៦០១ដល់៦៨២ គឺអាចកត់ត្រាខាងឥណទាននៃគណនីពាក់ព័ន្ធ ឬអាចកត់ត្រាខាងឥណពន្ធដោយប្រើសញ្ញាដក។**

**៨៥-គណនី ពន្ធលើបេតិកភ័ណ្ឌ " លេខ ៧០១ ":**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួន ទឹកប្រាក់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានមកពីប្រាក់ពន្ធលើបេតិកភ័ណ្ឌនានា។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនប្រាក់ចំណូលថវិកាពីពន្ធបេតិកភ័ណ្ឌដែលប្រមូលបាន

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិការដ្ឋបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>ចំណាំ</u> : គណនីលេខ ៧០១ ត្រូវចែកទៅជាអនុគណនី សម្រាប់ពន្ធប្រថាប់ត្រា - ពន្ធផ្ទេរមរតករវាងអ្នកនៅរស់ ពន្ធប្រថាប់ត្រា-ពន្ធផ្ទេរសិទ្ធិពីអ្នកស្លាប់ និងសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់។

**៨៦-គណនី ពន្ធលើទ្រព្យសម្បត្តិដែលបានកំណត់ " លេខ ៧០២ ":**

គណនីនេះបើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានមកពីពន្ធលើទ្រព្យសម្បត្តិដែលបានកំណត់។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនប្រាក់ចំណូលថវិកាពីពន្ធលើទ្រព្យសម្បត្តិដែលបានកំណត់ ដែលប្រមូលបាន

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល

នៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៧០២ ត្រូវចែកទៅជាអនុគណនី អាករសម្រាប់បំភ្លឺសាធារណៈ។

**៨៧-គណនី ពន្ធលើសេវាដែលបានកំណត់ "លេខ ៧០៣":**

គណនីនេះ បើកនៅតនាគារជាតិ ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានមកពីពន្ធលើសេវាដែលបានកំណត់។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនប្រាក់ចំណូលថវិកាពីពន្ធលើសេវាដែលបានកំណត់ដែលប្រមូលបាន

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ៧០៣ ត្រូវចែកទៅជាអនុគណនីសម្រាប់អាករលើការស្នាក់នៅ និងសម្រាប់ពន្ធសត្តឃាត។

**៨៨-គណនី អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិ ឬការអនុវត្តសកម្មភាព "លេខ ៧០៤":**

គណនីនេះបើកនៅតនាគារជាតិ ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានមកពីអាករលើសេវាដែលបានកំណត់។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនប្រាក់ចំណូលថវិកាពីអាករលើការប្រើប្រាស់ទ្រព្យសម្បត្តិ ឬការអនុវត្តន៍សកម្មភាពដែលប្រមូលបាន

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៧០៤ ត្រូវចែកទៅជាអនុគណនី សម្រាប់ពន្ធប៉ាតង់ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានយន្តគ្រប់ប្រភេទ។

**៨៩-គណនី ពន្ធលើអចលនទ្រព្យ "លេខ ៧០៧":**

គណនីនេះបើកនៅតនាគារជាតិ ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានមកពីពន្ធលើអចលនទ្រព្យដែលបានកំណត់។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាពីពន្ធលើអចលនទ្រព្យ ដែលប្រមូលបាន

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៧០៧ ត្រូវចែកទៅជាអនុគណនី ពន្ធលើអចលនទ្រព្យរូបវន្តបុគ្គល និងពន្ធលើអចលនទ្រព្យនីតិបុគ្គល។

**៩០-គណនី ផលនៃការជួលដីធ្លី "លេខ ៧២១":**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានមកពីផលពីការជួលដីធ្លី។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាពីការជួលដីធ្លីដែលប្រមូលបាន

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៧២១ ត្រូវចែកទៅជាអនុគណនីសម្រាប់សម្បទានពីរ៉ែ ការជួលកន្លែងលក់ដូរក្នុងទីផ្សារ ចំណូលពីចំណតរថយន្ត និងសម្រាប់ចំណូលពីចំណតជលយាន។

**៩១-គណនី សហគ្រាសសាធារណៈ រដ្ឋបាល និងសេវាទ្រព្យសម្បត្តិ "លេខ ៧៣១":**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានពីផលសហគ្រាសសាធារណៈរដ្ឋបាល និងសេវាទ្រព្យសម្បត្តិ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាពីសហគ្រាសសាធារណៈ រដ្ឋបាល និងសេវាទ្រព្យសម្បត្តិដែលប្រមូលបាន

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**៩២-គណនី ផលពីការគ្រប់គ្រងរដ្ឋបាល "លេខ ៧៣២":**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានពីការគ្រប់គ្រងរដ្ឋបាល។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានពីកំរៃរដ្ឋបាលនិងការអនុញ្ញាតិរដ្ឋបាលដែលប្រមូលបាន

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ហើយពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ ៧៣២ ត្រូវចែកទៅជាអនុគណនី សម្រាប់សេវាសុរិយោដី សេវាសំណង់ ចំណូលសម្រាប់ទម្រង់ការរដ្ឋបាល ចំណូលពីការអនុញ្ញាត្តិរដ្ឋបាល សេវាត្រួតពិនិត្យអនាម័យសត្វនៅសត្តឃាតដ្ឋាន និងសម្រាប់ចំណូលរដ្ឋបាលផ្សេងៗទៀត។

**៩៣-គណនី ការជួលទ្រព្យសម្បត្តិអចលត៍ "លេខ ៧៣៣":**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រចំនួនទឹកប្រាក់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានមកពីប្រាក់ពីការជួលទ្រព្យសម្បត្តិអចល័តនានា។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាបានពីថ្លៃឈ្នួលទ្រព្យសម្បត្តិអចល័តដែលប្រមូលបាន

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ។

ចំណាំ : គណនីលេខ៧៣៣ ត្រូវចែកទៅជាអនុគណនីសម្រាប់ចំណូលពីសត្តឃាតដ្ឋាន ការជួលកន្លែងលក់ដូរក្នុងទីផ្សារ ចំណូលពីកំពង់ចម្លង ចំណូលពីយៀគ្រី និងទីកន្លែងបែងចែកផលិតផល និងសម្រាប់ចំណូលពីកាស៊ីផ្សារ និងការជួលទ្រព្យសម្បត្តិអចល័តផ្សេងៗទៀត។

**៩៤-គណនី ផលពីការពិន័យ និងការដាក់ទណ្ឌកម្ម "លេខ ៧៤១" :**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានមកពីប្រាក់ពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាពីប្រាក់ផាកពិន័យ និងការដាក់ទណ្ឌកម្មដែលប្រមូលបាន

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ។

**៩៥-គណនី ផលពីការទប់ស្កាត់ និងបង្ក្រាបអំពើគេចពន្ធគយ "លេខ ៧៤២" :**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានមកពីការផាកពិន័យ និងបង្ក្រាបអំពើគេចពន្ធគយ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាពីការផាកពិន័យ និងបង្ក្រាបអំពើគេចពន្ធគយដែលប្រមូលបាន

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ។

**៩៦-គណនី ទាយជូទានសម្រាប់ដំណើរការដែលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ "លេខ ៧៥១":**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានមកពីការឧបត្ថម្ភពីថវិការដ្ឋ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាពីឧបត្ថម្ភធនដែលបានទទួលពីថវិការដ្ឋ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល នៃការិយបរិច្ឆេទ។

**៩៧-គណនី ទាយជ្ជទានសម្រាប់ដំណើរការដែលឧបត្ថម្ភពីថវិការាជធានី ខេត្ត "លេខ ៧៥២":**

គណនីនេះ បើកនៅតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានមកពីការឧបត្ថម្ភពីថវិការាជធានី ខេត្ត។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាពីឧបត្ថម្ភធនដែលបានទទួលពីថវិការាជធានី ខេត្ត

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**៩៨-គណនី ទាយជ្ជទានសម្រាប់ដំណើរការដែលឧបត្ថម្ភពីថវិកាក្រុង ស្រុក ខណ្ឌ "លេខ ៧៥៣":**

គណនីនេះ បើកនៅតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានមកពីការឧបត្ថម្ភពីថវិកាក្រុង ស្រុក ខណ្ឌ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាពីឧបត្ថម្ភធនដែលបានទទួលពីថវិកាក្រុង ស្រុក ខណ្ឌ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**៩៩-គណនី ការចូលរួមធនធានពីសមាសភាគអភិវឌ្ឍមូលដ្ឋាន "លេខ ៧៥៤":**

គណនីនេះ បើកនៅតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានមកពីការចូលរួមធនធានពីសមាសភាគអភិវឌ្ឍមូលដ្ឋាន។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាបានមកពីការចូលរួមធនធានពីសមាសភាគអភិវឌ្ឍមូលដ្ឋាន

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**១០០-គណនី ការចូលរួមធនធានពីដៃគូអភិវឌ្ឍ "លេខ ៧៥៥":**

គណនីនេះ បើកនៅតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានមកពីការចូលរួមធនធានពីដៃគូអភិវឌ្ឍ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាបានមកពីការចូលរួមធនធានពីដៃគូអភិវឌ្ឍ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល

នៃការិយបរិច្ឆេទ។

**១០១-គណនី ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ "លេខ ៧៥៦**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានមកពីចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារដែលប្រគល់ដោយក្រសួង ស្ថាប័ន អង្គភាព មន្ទីរ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាបានមកពីការអនុវត្តមុខងារជាភ្នាក់ងារ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>ចំណាំ</u> : គណនីលេខ៧៥៦ ត្រូវចែកទៅជាអនុគណនីសម្រាប់ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារពីក្រសួង ស្ថាប័ន ពីមន្ទីរជំនាញ ពីរាជធានី ខេត្ត និងពីក្រុង ស្រុក ខណ្ឌ។

**១០២-គណនី ចំណូលឧបត្ថម្ភពីប្រភពផ្សេងៗ "លេខ ៧៥៨" :**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានមកពីការឧបត្ថម្ភពីប្រភពផ្សេងៗទៀត។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនប្រាក់ចំណូលថវិកាពីឧបត្ថម្ភធនដែលបានទទួលពីប្រភពផ្សេងៗ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**១០៣-គណនី ផលហិរញ្ញវត្ថុផ្សេងទៀត "លេខ ៧៦៨" :**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានមកពីផលហិរញ្ញវត្ថុផ្សេងៗទៀត។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនប្រាក់ចំណូលថវិកាពីផលហិរញ្ញវត្ថុដែលបានទទួលពីប្រភពផ្សេងៗ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**១០៤-គណនី ផលពីការលក់អចលកម្ម "លេខ ៧៧៥" :**

គណនីនេះបើករតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានមកពីការលក់អចលកម្មរូបី និងអរូបី។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានពីការលក់អចលកម្ម

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

**១០៥-គណនី ចំណែកនៃឧបត្ថម្ភកធនវិនិយោគផ្ទេរទៅគណនីលទ្ធផល " លេខ ៧៧៧ " :**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្តប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ចាត់ជាចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលស្មើនឹងចំណែកនៃតម្លៃអចលកម្មដែលបានគិតរំលស់។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាស្មើនឹងប្រាក់រំលស់អចលកម្ម

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>ចំណាំ</u> : ការកត់ត្រាខាងឥណទាន នៃគណនីនេះបដិភាគនឹងខាងឥណពន្ធនៃគណនី ឧបត្ថម្ភកធនវិនិយោគផ្ទេរទៅគណនីលទ្ធផល (លេខ ១៣៩)។

**១០៦-គណនី ការខារនៃវដ្តទេយ្យ " លេខ ៧៨ " :**

គណនីនេះ បើកនៅរតនាគាររាជធានី ខេត្ត ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការផលិតសាងសង់អចលកម្មដោយរដ្ឋបាលថ្នាក់ក្រោមជាតិផ្ទាល់ ហើយនៅដំណាច់ឆ្នាំត្រូវប្រមូលផ្តុំតួលេខកត់ត្រាលើគណនីនេះ ដើម្បីអោយមានតុល្យភាពជាមួយទឹកប្រាក់ចំណាយថវិកាពាក់ព័ន្ធការសាងសង់អចលកម្ម។ គណនីនេះកត់ត្រាបដិភាគនឹងតម្លៃអចលកម្មដែលពាក់ព័ន្ធ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាចំនួនប្រាក់ស្មើចំណាយថវិកាចរន្តដែលមានការពាក់ព័ន្ធការវិនិយោគ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ។

<u>**ចំណាំ:**</u>

ចំពោះការបន្ថយចំណូលថវិកាលើគណនីលេខ ៧០១ដល់៧៧៧ គឺអាចកត់ត្រាខាងឥណពន្ធនៃគណនីពាក់ព័ន្ធ ឬអាចកត់ត្រាខាងឥណទានដោយប្រើសញ្ញាដក។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ: ៩៥៥៨ ឧ.រ.ថ-គរ-ប្រក-

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១២

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ ១៦៨៤/០៨ គ.វ.ក ចុះថ្ងៃទី៣០.០៦.២០០៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន លី ឈួង សំណង់ & អាហ័រណ នីហ័រណ ចុះថ្ងៃទី១៩.០៩.២០១២

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន លី ឈួង សំណង់ & អាហ័រណ នីហ័រណ (LY CHHUONG CONSTRUCTION & IMPORT EXPORT CO.,LTD.) តំណាងដោយលោក លី ឈួង សញ្ជាតិខ្មែរ អាយុ ៥០ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៣៧៨៥៦៨ ចុះថ្ងៃទី ១៦.០៤.២០០២ មានអាសយដ្ឋានបច្ចុប្បន្នះ៥៨ ផ្លូវលេខ២៤០ ក្រុម១២ សង្កាត់ទូលទំពូង២ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ ដោយមានសញ្ញា ដូចខាងក្រោម ៖

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| -បន្ទះក្រាល | ២៣៩៥ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax : 855-23-428263

-បន្ទះជញ្ជាំង ២៣៩៥
-បន្ទះហ្វីប្រូ ២៣៩៥
-ក្បឿង ២៣៩៥

**ផ្លាកឈ្មោះរោងចក្រ៖** " *រោងចក្រផលិតបន្ទះក្រាល បន្ទះជញ្ជាំង បន្ទះហ្វីប្រូ និងក្បឿង* "
**ទីតាំងរោងចក្រ ៖** " *ភូមិព្រីង ឃុំលាំងចក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ* "

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែល បានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមាន ជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មីនៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែ ទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបាន កំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មាន ជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៥៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាម បទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការ ចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោម តាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមាន ប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** ប្រកាសលេខ ៨៧០ ឧរថ.កឧប្រក ចុះថ្ងៃទី០៩.១០.២០០៨ របស់ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ស្តីពីការបង្កើតរោងចក្រផលិតបន្ទះក្រាល បន្ទះជញ្ជាំង បន្ទះហ្វីប្រូ និងក្បឿង របស់ក្រុមហ៊ុន លី ឈួង សំណង់ & អាហ័រណេ នីហ័រណេ ត្រូវចាត់ទុក ជានិរាករណ៍ ។

**ប្រការ១៥:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

**ប្រការ១៦:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ សែម

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តកំពង់ស្ពឺ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**
**Ministry of Industry, Mines and Energy**

លេខ: ៩៤៩ ១៥ ឧ.ក.រ -ប្រក-

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១២

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

